ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

# ទស្សនាទាន

## ស្ដីពី

## ការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

មិថុនា ២០២៦

# មាតិកា

**១. សេចក្តីផ្តើម**..........១
១.១ ការវិវត្តនៃវិស័យពាណិជ្ជកម្មកម្ពុជា..........១
១.២ មូលបញ្ហា..........៥
១.៣ គោលបំណង និងលទ្ធផលរំពឹងទុក..........៨
១.៤ វិសាលភាព ដែនកំណត់ និងអភិក្រម..........៩
**២. វិធីសាស្ត្រក្នុងការរៀបចំក្រម**..........១១
២.១ វិធីសាស្ត្រនៃការរៀបចំក្រម- ឧត្តមានុវត្តន៍អន្តរជាតិ..........១១
២.១.១ ការប្រមូលផ្តុំ ការចងក្រង និងក្រម..........១២
២.១.២. យន្តការស្ថាប័ននៃការរៀបចំក្រម..........១៧
២.១.៣ គុណប្រយោជន៍ និងគុណវិបត្តិ នៃការប្រមូលផ្តុំ ការចងក្រងក្រម..........១៨
២.២ វិធីសាស្ត្រនៃការរៀបចំក្រមនៅកម្ពុជា..........២១
**៣. អំពីពាណិជ្ជកម្ម**..........២១
៣.១ ប្រភេទនៃទំនាក់ទំនងពាណិជ្ជកម្ម..........២១
៣.២ ក្របខ័ណ្ឌគតិយុត្តក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិ..........២២
៣.២.១ ក្របខ័ណ្ឌនីតិពាណិជ្ជកម្មអន្តរជាតិសាធារណៈ..........២៣
៣.២.២ ក្របខ័ណ្ឌច្បាប់ពាណិជ្ជកម្មអន្តរជាតិឯកជន..........២៦
៣.៣ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យពាណិជ្ជកម្មកម្ពុជា..........៣០
៣.៤ ការសិក្សាស្រាវជ្រាវពីក្រមពាណិជ្ជកម្មពីប្រទេសអភិវឌ្ឍ និងប្រទេសដែលមានប្រព័ន្ធច្បាប់ស្រដៀងនឹងកម្ពុជា..........៣២
**៤. ក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា**..........៣៣
៤.១ និយមន័យនីតិពាណិជ្ជកម្មសម្រាប់កម្ពុជា..........៣៣
៤.២ ក្របខ័ណ្ឌនៃក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា..........៣៤
៤.៣ វិធីសាស្ត្រនៃការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា..........៣៦
៤.៤ សេចក្តីព្រាងមាតិកានៃក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា..........៣៦
**៥. ការគ្រប់គ្រងធនធាន**..........៣៦
៥.១ ធនធានមនុស្ស..........៣៦
៥.២ ធនធានហិរញ្ញវត្ថុ..........៣៧

**៦. ផែនការសកម្មភាពនិងក្របខ័ណ្ឌពេលវេលា** ............ ៣៧
**ឧបសម្ព័ន្ធទី១ វិធីសាស្ត្រក្នុងការរៀបចំក្រមនៅកម្ពុជា** ............ ៣៩
១.១ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ............ ៣៩
១.២. ក្រមព្រហ្មទណ្ឌ ............ ៤២
១.៣ ក្រមបរិស្ថាននិងធនធានធម្មជាតិ (ក្រមបរិស្ថាន) ............ ៤៣
**ឧបសម្ព័ន្ធទី២ គម្រោងរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា** ............ ៤៧
**ឧបសម្ព័ន្ធទី៣ បញ្ជីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនិងព័ត៌មានផ្សេងៗ ក្នុងក្របខ័ណ្ឌ** WTO ............ ៤៩
**ឧបសម្ព័ន្ធទី៤ បញ្ជីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម** ............ ៥៤
**ឧបសម្ព័ន្ធទី៥ តារាងផែនការសកម្មភាពនិងក្របខ័ណ្ឌពេលវេលា** ............ ៦៣
**ឧបសម្ព័ន្ធទី៦ សេចក្តីព្រាងមាតិកា "ក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា"** ............ ៦៥

# ទស្សនាទាន ស្តីពី
# "ការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា"

## ១. សេចក្តីផ្តើម

### ១.១ ការវិវត្តនៃវិស័យពាណិជ្ជកម្មកម្ពុជា

ពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា បានវិវត្តចេញពីប្រពៃណីដ៏យូរលង់នៃការដោះដូរទំនិញក្នុងតំបន់ ទៅជាប្រព័ន្ធសេដ្ឋកិច្ចមួយដែលផ្អែកលើការនាំចេញ។ ក្នុងប្រវត្តិសាស្រ្ត កម្ពុជាគឺជាទឹកដីដែលសម្បូរទៅដោយវាលទំនាប ទន្លេ និងស្ថិតនៅចំកណ្តាលនៃផ្លូវពាណិជ្ជកម្ម និងផ្លូវទឹកសំខាន់ៗ តភ្ជាប់ប្រទេសចិនទៅកាន់ប្រទេសឥណ្ឌា ដែលបានផ្សារភ្ជាប់សកម្មភាពពាណិជ្ជកម្មកម្ពុជាទៅនឹងបណ្តាញពាណិជ្ជកម្មអាស៊ី។[1] នៅសម័យអាណាចក្រភ្នំឬ ហ្វូណន ឈ្មួញចិន និងឥណ្ឌាបានធ្វើដំណើរមកដល់ឆ្នេរសមុទ្រនៃប្រទេសកម្ពុជាបច្ចុប្បន្ន ដើម្បីធ្វើការដោះដូរទំនិញដូចជា ក្រណាត់សូត្រ និងលោហធាតុ ជាថ្នូរនឹងគ្រឿងទេស ឈើក្រអូប ភ្លុកដំរី និងមាសជាដើម។[2] លុះដល់សម័យអង្គរ ពាណិជ្ជកម្មជាតិ និងពាណិជ្ជកម្មអន្តរជាតិ បានរីកលូតលាស់យ៉ាងខ្លាំង ដោយមានវិស័យកសិកម្មជាមូលដ្ឋានសេដ្ឋកិច្ចចម្បង ដែលបានធ្វើឱ្យអំណាចនៃចក្រភពអង្គរ រីកចម្រើននិងជឿនលឿនគួរឱ្យកត់សម្គាល់នៅក្នុងប្រវត្តិសាស្រ្តកម្ពុជា។ បន្ថែមពីនេះ ការអភិវឌ្ឍប្រព័ន្ធធារាសាស្រ្ត និងការរៀបចំដែនដីដ៏ធំធេងនៅអង្គរ បានជួយបង្កើតឱ្យមាន អតិរេកស្បៀង សម្រាប់ទ្រទ្រង់ប្រជាជន ការកសាងប្រាសាទ និងពង្រឹងអំណាចអាណាចក្រ។ នៅសម័យក្រោយអង្គរ រចនាសម្ព័ន្ធសេដ្ឋកិច្ចបានវិវត្តពីកសិកម្មដីគោក មកជាពាណិជ្ជកម្មតាមដងទន្លេ ដោយទាញយកសក្តានុពលយុទ្ធសាស្រ្តនៃចំណុចប្រសព្វទន្លេមេគង្គ និងទន្លេសាប ដើម្បីគ្រប់គ្រងចរន្តទំនិញក្នុងតំបន់។ របត់នេះបានផ្លាស់ប្តូរម្តងទៀតក្នុងសម័យអាណានិគមបារាំង ទៅជាសេដ្ឋកិច្ចនាំចេញតាមបែបអាណានិគម ដែលផ្តោតលើការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងផ្លូវដែក ដើម្បីបម្រើដល់ការធ្វើពាណិជ្ជកម្ម ដូចជាការនាំចេញកៅស៊ូ និងស្រូវអង្ករទៅកាន់ទីផ្សារអន្តរជាតិជាដើម។

ស្របនឹងការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ច និងស្ថិតក្រោមនឹមអាណានិគមរបស់បារាំងរាជរដ្ឋាភិបាលកម្ពុជាបានធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធច្បាប់ខ្មែរតាមលំនាំបារាំងនាឆ្នាំ១៨៨៤ ដោយបានបោះជំហានទៅរកការកសាងប្រព័ន្ធច្បាប់តាមប្រព័ន្ធច្បាប់ស៊ីវិល (Civil Law) ហើយក្នុងនោះ ក្រមជាមូលដ្ឋានដំបូងៗ រួមមាន រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ក្រមព្រហ្មទណ្ឌឆ្នាំ១៩០៥ ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ និងក្រមពាណិជ្ជកម្មឆ្នាំ១៩៦១ ត្រូវបានលេចរូបរាងឡើង សម្រាប់ការដឹកនាំ គ្រប់គ្រងប្រទេសនិងប្រជាជន។

---

[1] Leonard C Overton and David P Chandler, "Cambodia," in Encyclopædia Britannica, July 26, 1999, https://www.britannica.com/place/Cambodia.

[2] David P.Chandler,"Cambodia-History | Britannica," in *Encyclopædia Britannica*, 2020, https://www.britannica.com/place/Cambodia/History.; Leonard C Overton and David P Chandler, "Cambodia," in Encyclopædia Britannica, July 26, 1999, https://www.britannica.com/place/Cambodia.

បន្ទាប់ពីទទួលបានឯករាជ្យក្នុងឆ្នាំ១៩៥៣ របបសង្គមរាស្ត្រនិយមបានកើតឡើងជាមួយនឹងសមិទ្ធផលសំខាន់ៗជាច្រើនដូចជាការកសាងហេដ្ឋារចនាសម្ព័ន្ធ វិស័យឧស្សាហកម្មកែច្នៃ វិស័យអប់រំ វិស័យសុខាភិបាល និងវិស័យពាណិជ្ជកម្មអន្តរជាតិ តាមរយៈការវិនិយោគ ដែលបានកើតចេញពីការដឹកនាំ និងការគ្រប់គ្រងតាមគោលការណ៍ច្បាប់ និងវិធានច្បាស់លាស់ របស់**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ**។

បន្ទាប់ពីការឡើងកាន់អំណាចរបស់រដ្ឋាភិបាលនៃរបបសាធារណរដ្ឋខ្មែរ តាមរយៈរដ្ឋប្រហារយោធានៅខែមីនា ឆ្នាំ១៩៧០ រដ្ឋធម្មនុញ្ញទីពីររបស់កម្ពុជាត្រូវបានប្រកាសដាក់ឱ្យប្រើនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧២ ដើម្បីជំនួសរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧។ រដ្ឋធម្មនុញ្ញទីពីរនេះត្រូវបានអនុម័តឡើងដោយទទួលឥទ្ធិពលពីរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋទី៥ របស់រដ្ឋាភិបាលបារាំង និងរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក ដែលមានប្រព័ន្ធរដ្ឋាភិបាលបែបប្រធានាធិបតីនិយម តាមលទ្ធិប្រជាធិបតេយ្យសេរី។ ក្នុងអំឡុងពេលនោះ ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ នៅតែបន្តមានសុពលភាពអនុវត្ត រីឯច្បាប់ស្តីពីការងារលើកដំបូងបង្អស់របស់កម្ពុជា ក៏ត្រូវបានអនុម័តក្នុងឆ្នាំ១៩៧២ ប៉ុន្តែការអនុវត្តច្បាប់នេះហាក់ដូចជាជួបប្រទះនូវភាពរឹករវផ្នែកសង្គម និងនយោបាយជាមួយនឹងការលេចឡើងនៃសង្គ្រាមស៊ីវិលនៅកម្ពុជាផងដែរ។

ការដួលរលំនៃរបបសាធារណរដ្ឋខ្មែរក្នុងឆ្នាំ១៩៧៥ បានដឹកនាំកម្ពុជាទៅកាន់របបមួយផ្សេងទៀតជាមួយនឹងរដ្ឋធម្មនុញ្ញទីបីរបស់ខ្លួន ដែលត្រូវបានប្រកាសដាក់ឱ្យប្រើនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ដោយមានឈ្មោះផ្លូវការថា "កម្ពុជាប្រជាធិបតេយ្យ"។[៣] ក្នុងអំឡុងពេលនោះ ខ្មែរក្រហមបានលុបបំបាត់ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត រូបិយប័ណ្ណ[៤] កម្មសិទ្ធិឯកជន(លើកលែងរបស់របរប្រើប្រាស់ប្រចាំថ្ងៃ) ទីផ្សារ និងធនាគារ[៥] ដោយបង្ខំឱ្យប្រជាជនធ្វើស្រែដើម្បីសម្រេចទិន្នផលស្រូវ ៣តោន ក្នុងមួយហិចតា[៦] ជីកប្រឡាយ និងសាងសង់ទំនប់ទឹកដោយប្រើដៃនិងឧបករណ៍បុរាណ ដើម្បីជានាការធ្វើស្រែគ្រប់រដូវ[៧]។ នៅក្នុងរបបនេះ ពាណិជ្ជកម្មក្នុងស្រុកត្រូវបានលុបបំបាត់ទាំងស្រុង ដោយជំនួសមកវិញនូវយន្តការរដ្ឋបាលកណ្តាល ដែលរដ្ឋមានតួនាទីជាអ្នកប្រមូលផល និងបែងចែកស្បៀងតាមកម្រិតកំណត់ ដោយការណ៍នេះបានបង្កឱ្យមានវិបត្តិអត់ឃ្លានយ៉ាងធ្ងន់ធ្ងរ។ ដោយឡែក ចំពោះពាណិជ្ជកម្មក្រៅប្រទេស ទោះបីជាកម្ពុជាស្ថិតក្នុងស្ថានភាពឯកោក្តី ក៏នៅតែមានសកម្មភាពនាំចេញក្នុងកម្រិត

[៣] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ មហាសន្និបាតជាតិលើទី៣ អនុមតិថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ១៩៧៥។

[4] ECCC, Co-Prosecutor v. NOUN Chea and KHIEU Samphan, Case 002/01 JUDGEMENT (Trial Chamber September 19, 2007), Case No. 002/19-09 2007/ECCC/TC, E313, paras.493 and 106.

[៥] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ, មាត្រា២ មាត្រា៤ មាត្រា១២ និងមាត្រា១៧។

[6] Supra 4, paras.604.

[7] ECCC, Co-Prosecutor v. NOUN Chea and KHIEU Samphan, Case 002/02 JUDGEMENT (Trial Chamber September 19, 2007), Case No. 002/19-09 2007/ECCC/TC, E465, paras1088, 1479, 1488.

កំណត់ តាមរយៈការដោះដូរអង្ករ កៅស៊ូ និងផលនេសាទ ដើម្បីទទួលបានមកវិញនូវសញ្ញាវុធ គ្រឿងចក្រ ឧបករណ៍ប្រើប្រាស់ និងប្រេងឥន្ធនៈ សម្រាប់បម្រើឱ្យគោលដៅបដិវត្តន៍។[៨]

ក្រោយថ្ងៃជ័យជម្នះ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ស្ថានភាពពាណិជ្ជកម្មកម្ពុជាបានចាប់ផ្តើមងើបឡើងវិញពីចំណុចសូន្យ ក្នុងស្ថានភាពដែលរចនាសម្ព័ន្ធសេដ្ឋកិច្ចត្រូវបានបំផ្លាញចោលខ្ទេចខ្ទី។ ដំណើរការស្តារឡើងវិញនេះ អាចបែងចែកជាពីរបត់សំខាន់ៗ។ ក្នុងដំណាក់កាលដំបូងឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៨ កម្ពុជាបានអនុវត្ត ប្រព័ន្ធសេដ្ឋកិច្ចផែនការ តាមលំនាំប្រទេសសង្គមនិយម ដោយចាប់ផ្តើមបោះពុម្ព និងដាក់ឱ្យប្រើប្រាស់ប្រាក់រៀលឡើងវិញនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០ ដើម្បីស្តារទំនុកចិត្តពីប្រជាជន បង្កើតទីផ្សារ និងសកម្មភាពដោះដូរទំនិញ។ រដ្ឋបានដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រង និងការចែកចាយទំនិញចាំបាច់ ជាមួយនឹងការលេចរូបរាងឡើងវិញនូវ ទីផ្សារសេរីខ្នាតតូចសម្រាប់សេដ្ឋកិច្ចគ្រួសារ រួមទាំងការធ្វើពាណិជ្ជកម្មក្រៅប្រទេសជាមួយបណ្តាប្រទេសជាមិត្ត ដូចជាសហភាពសូវៀត និងវៀតណាម តាមរយៈកិច្ចព្រមព្រៀងដោះដូរទំនិញរវាងរដ្ឋ និងរដ្ឋ។

នៅចុងទសវត្សរ៍ឆ្នាំ៨០ កម្ពុជាបានឈានចូលរបត់ទីពីរ គឺការផ្លាស់ប្តូរទៅរកសេដ្ឋកិច្ចទីផ្សារសេរី តាមរយៈកំណែទម្រង់សេដ្ឋកិច្ចស៊ីជម្រៅក្នុងឆ្នាំ១៩៨៩ ដែលក្នុងនោះរដ្ឋបានទទួលស្គាល់កម្មសិទ្ធិឯកជនលើដីធ្លី និងផ្ទះសម្បែង ក៏ដូចជាការលុបបំបាត់លើការនាំចេញ និងការនាំចូលផ្តាច់មុខ។ រួមផ្សំនឹងជោគជ័យលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ បានជំរុញឱ្យកម្ពុជាធ្វើសមាហរណកម្មខ្លួនយ៉ាងឆាប់រហ័សទៅក្នុងតំបន់ និងសកលលោក ដោយចាប់ផ្តើមតភ្ជាប់ពាណិជ្ជកម្មជាមួយបណ្តាប្រទេសក្នុងអាស៊ាន និងពិភពលោក ដែលបាននាំឱ្យមានការហូរចូលជាបន្តបន្ទាប់នៃទំនិញប្រើប្រាស់ និងការវិនិយោគផ្ទាល់ពីបរទេស (Foreign Direct Investment)។

ក្នុងរយៈពេលជាង ២ទសវត្សរ៍មកនេះ តាមរយៈយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណ ទាំង៤ដំណាក់កាល ដែលជាដំណាក់កាលនៃការកសាងជាតិ បានផ្តោតសំខាន់លើការស្តារ និងការកសាងប្រទេស ដែលទើបងើបចេញពីសង្គ្រាម ការរក្សាសុខសន្តិភាព សណ្តាប់ធ្នាប់សង្គម ការធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធនិងនិម្មាបនកម្មតំបន់និងសកល ការអភិវឌ្ឍនិងការរក្សាស្ថិរភាពសង្គម-សេដ្ឋកិច្ច និងការលើកកម្ពស់ជីវភាពប្រជាជន។ តាមរយៈគោលនយោបាយឈ្នះ ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាអតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កម្ពុជាបានបោះជំហានយ៉ាងស្វាហាប់ក្នុងការធ្វើទំនើបភាវូបនីយកម្មច្បាប់ស្របតាមស្តង់ដាអន្តរជាតិ ដោយប្រកាន់ខ្ជាប់ខ្ជួននូវគោលការណ៍នីតិរដ្ឋជាមូលដ្ឋានគ្រឹះដែលបានចារឹកនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ដោយឈរលើគុណតម្លៃស្នូល រួមមានប្រព័ន្ធនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស ការគោរពសិទ្ធិមនុស្ស សិទ្ធិបុគ្គល និងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ។ ជាក់ស្តែងក្នុងវិស័យពាណិជ្ជកម្ម ទោះបីជាកម្ពុជា ជាប្រទេសដែលមាន

[8] Supra 4, paras. 400-409.

សេដ្ឋកិច្ចតូច ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជា ជឿជាក់លើអត្ថប្រយោជន៍នៃសកលភាវូបនីយកម្ម និងកិច្ចសហប្រតិបត្តិការអន្តរជាតិដោយឈរលើវិធានគតិយុត្ត ដែលកត្តានេះបានជំរុញឱ្យកម្ពុជាចូលជាសមាជិកពេញសិទ្ធិរបស់អង្គការពាណិជ្ជកម្មពិភពលោក នៅឆ្នាំ២០០៤ ដោយបានសន្យាចងពន្ធគយលើគ្រប់មុខទំនិញ និងបើកច្រកទីផ្សារពាណិជ្ជកម្មផ្នែកសេវាកម្មប្រមាណជាង ៩៤វិស័យនិងអនុវិស័យ។

ផ្អែកលើសមិទ្ធផលដែលទទួលបានក្នុងរយៈពេល ២៥ឆ្នាំកន្លងទៅ និងការពិនិត្យ វាយតម្លៃនិន្នាការតំបន់និងសកល ក៏ដូចជាការសម្លឹងទៅមុខសម្រាប់រយៈពេល ២៥ឆ្នាំបន្តទៀត រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតនិងភាពប្រាកដនិយមរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដែលជាយុទ្ធសាស្ត្រអភិវឌ្ឍសង្គម សេដ្ឋកិច្ចរយៈពេលវែង ឆ្ពោះទៅការកែប្រែកម្ពុជា ឱ្យក្លាយជាសង្គមជាតិមួយដ៏រស់រវើក មានសុខសន្តិភាព ឋិតថេរចីរកាល មានស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សាធារណៈមាំមួន មានការគោរពច្បាប់និងនីតិរដ្ឋ និងក្លាយជាប្រទេសមានចំណូលខ្ពស់និងមានសេដ្ឋកិច្ចធន់រឹងមាំ ប្រកបដោយប្រសិទ្ធភាព ភាពប្រកួតប្រជែង បើកចំហ បរិយាបន្ន និងចីរភាព។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់រាជរដ្ឋាភិបាល ដូចដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងការកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យឆ្នាំ២០៥០ ក៏ដូចជាដោះស្រាយបញ្ហានៃស្ថានភាពច្បាប់កម្ពុជាបច្ចុប្បន្ន ដែលមានច្រើនប្រភេទ ចម្រុះវិស័យ អសង្គតិភាព មិនស៊ីចង្វាក់គ្នា ប្រទាំងទិសគ្នា ផ្ទុយគ្នា មិនឯកភាពគ្នាទាំងការប្រើប្រាស់ពាក្យច្បាប់ ទាំងការកំណត់ខ្លឹមសារ ឬអភិក្រមនៃការបកស្រាយខ្លឹមសារច្បាប់ ជាពិសេសច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យតែមួយ តែមិនប្រទាក់ក្រឡាគ្នា មិនស្របគ្នា មិនបំពេញឱ្យគ្នា រីឯវិស័យមួយចំនួននៅមានគម្លាតរវាងគោលនយោបាយ/យុទ្ធសាស្ត្រ និងច្បាប់ និងគម្លាតរវាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត **រាជរដ្ឋាភិបាលបានប្រកាសដាក់ឱ្យប្រើប្រាស់ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល** កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥ ដែលជាមគ្គុទេសក៍បង្ហាញផ្លូវដំបូង ក្នុងការដឹកនាំ គ្រប់គ្រង និងអនុវត្តការងារទាក់ទងនឹងការកែទម្រង់ច្បាប់ ដោយគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ជានិម្មាបនករនៃប្រព័ន្ធច្បាប់និងវប្បធម៌នីតិរដ្ឋ ដោយផ្អែកលើគុណតម្លៃប្រវត្តិសាស្ត្ររបស់កម្ពុជានិងគុណតម្លៃសាកលក្នុងបេសកកម្មកែទម្រង់ច្បាប់កម្ពុជាឱ្យទៅជាប្រព័ន្ធច្បាប់មួយដែលមានឯកភាព ប្រសិទ្ធភាព សមានគតិភាព ឧត្តមានុភាពគតិយុត្ត និងសន្តិសុខគតិយុត្ត ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ និងបរិការណ៍កម្ពុជា។ ក្នុងស្មារតីនេះ ការរៀបចំទស្សនាទានស្តីពីការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា ជាដំណោះស្រាយមួយក្នុងដំណោះស្រាយជាច្រើនលើបញ្ហាប្រឈមចំពោះមុខ និងជាការងារអាទិភាពនៃការងារកែទម្រង់ច្បាប់ ស្របតាមយុទ្ធសាស្ត្រគន្លឹះដែលបានដាក់ចេញក្នុង កម្មវិធីទី២ ការរៀបចំផែនការតាក់តែងក្រម (ក្រមនីយកម្ម) តាមវិស័យ និងបានដាក់បញ្ចូលក្នុងគោលដៅទី៤ ដឹកនាំនិងសម្របសម្រួលរៀបចំ

ក្របខ័ណ្ឌតាក់តែងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ក្នុងផែនការសកម្មភាពឆ្នាំ២០២៥-២០២៨ របស់ គ.ក.ច. និងអគ្គលេខាធិការ គ.ក.ច.។

**វិស័យពាណិជ្ជកម្ម** គឺជាសសរស្តម្ភសេដ្ឋកិច្ចដ៏សំខាន់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ច ផលិតកម្ម និងបង្កើនឱកាសការងារ។ ក្នុងសភាពការណ៍នៃភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ ភាពមិនអាចប៉ាន់ស្មានបាននៃសេដ្ឋកិច្ចសកល អំពើឈ្លានពានព្រំដែន ក៏ដូចជាក្នុងដំណើរនៃការរក្សាចីរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា និងការកសាងមូលដ្ឋានគ្រឹះនិងភាពធន់នៃការអភិវឌ្ឍឱ្យកាន់តែរឹងមាំ រាជរដ្ឋាភិបាលកម្ពុជាបានរក្សាគោលជំហរយ៉ាងម៉ឺងម៉ាត់ក្នុងការថែរក្សាសុខសន្តិភាព និងស្ថិរភាពនយោបាយនិងសេដ្ឋកិច្ចក្នុងប្រទេស តាមរយៈការជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងភាពធន់ ដើម្បីធ្វើយ៉ាងណាធានានិរន្តរភាពនិងវឌ្ឍនភាពនៃសកម្មភាពសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ដោយប្រកាន់យកគោលនយោបាយគាំទ្រធុរកិច្ច (pro-business policy) ជានាបរិយាកាសធុរកិច្ច ដោយផ្សារភ្ជាប់ជាមួយផលប្រយោជន៍របស់ប្រជាជន និងប្រទេសជាតិទាំងមូល។ ក្នុងន័យនេះ ការលើកកម្ពស់ និងការពង្រឹងគុណភាពនៃការតាក់តែង ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ដោយសង្គតិភាព និងអនុលោមភាពគតិយុត្តនៃការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងវិស័យពាណិជ្ជកម្ម ស្របតាមនិយាមអន្តរជាតិ និងបរិការណ៍កម្ពុជា នឹងធានាបាននូវគុណប្រយោជន៍ ភាពជឿទុកចិត្តបាន តម្លាភាព និងភាពស្មើគ្នាចំពោះមុខច្បាប់ក្នុងការប្រកួតប្រជែង បើកចំហ ស្រួលស្វែងរក ងាយអនុវត្ត សម្រាប់ការធ្វើធុរកិច្ច ពាណិជ្ជកម្ម វិនិយោគ ហើយក៏ជាចំណែកមួយដ៏សំខាន់ក្នុងការចូលរួមការកសាងវប្បធម៌នីតិរដ្ឋ ក៏ដូចជាការរក្សាសុខសន្តិភាព និងការអភិវឌ្ឍប្រទេសក្នុងរយៈពេលវែង។

## ១.២ មូលបញ្ហា

ក្នុងគោលដៅលើកស្ទួយផលិតកម្ម ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងការនាំចេញតាមរយៈការធ្វើពិពិធកម្មទីផ្សារ សំដៅជំរុញកំណើន និងបង្កើនល្បឿនសមាហរណកម្មសេដ្ឋកិច្ច ពាណិជ្ជកម្មតំបន់ និងសកលលោក ក្រសួងពាណិជ្ជកម្ម និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា បានធ្វើការកែទម្រង់រចនាសម្ព័ន្ធរដ្ឋបាលនិងគ្រប់គ្រង ការអភិវឌ្ឍស្ថាប័ន ធនធានមនុស្ស ជាពិសេសការកសាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយពាណិជ្ជកម្មជាច្រើនសន្ទឹកសន្ធាប់។ បន្ថែមពីនេះ តាមរយៈអត្ថបទវិភាគរបស់ធនាគារអភិវឌ្ឍន៍អាស៊ី "ឱកាសអបអរ និងបញ្ហាប្រឈមផ្នែកពាណិជ្ជកម្មថ្មី សម្រាប់កម្ពុជា" ឆ្នាំ២០២៣ ដែលកម្ពុជាអាចងើបចេញពីបញ្ជីប្រទេសអភិវឌ្ឍន៍តិចតួចឆ្នាំ២០២៩ នឹងនាំមកនូវទាំងគុណសម្បត្តិ និងគុណវិបត្តិ ដែលត្រូវត្រៀមខ្លួនឱ្យបានរួចរាល់ ក្នុងការទទួលយកបញ្ហាប្រឈមថ្មីៗ ដូចជាការនាំចេញដោយរួចពន្ធ ការបង់ពន្ធរាល់ការនាំចេញខុសគ្នាក្នុងរង្វង់១៥% ទៅតាមប្រភេទទំនិញ ការកើនឡើងថ្លៃ និងការរៀបចំវិធីសាស្ត្រឆ្ពោះទៅរកភាពស្មើគ្នាសម្រាប់សហគ្រាសវិនិយោគបរទេស (Negative list approach) ដើម្បីសេរីភាវូបនីយកម្មពាណិជ្ជកម្ម សេវាកម្ម កាន់តែទូលំទូលាយ និងភាពស៊ីចង្វាក់គ្នានៃបទប្បញ្ញត្តិ និងតម្លាភាព។

ជាមួយនឹងវឌ្ឍនភាព និងទស្សនវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាល ក្នុងការលើកស្ទួយវិស័យពាណិជ្ជកម្មក្នុងស្រុក និងការវិនិយោគ ដើម្បីកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍជាតិកម្ពុជា បញ្ហាជាសារវន្តមួយចំនួនក៏នៅតែមាន/បានលេចរូបរាងឡើង ដូចខាងក្រោមៈ

- វិស័យពាណិជ្ជកម្ម ជាវិស័យសំខាន់និងប្រទាក់ក្រឡាជាមួយនឹងគោលនយោបាយនៃវិស័យផ្សេងៗទៀត ដែលជាហេតុនាំឱ្យក្រសួង ស្ថាប័នភាគច្រើនបំពេញតួនាទី ជាន់សមត្ថកិច្ចគ្នាក្នុងការអនុវត្តគោលនយោបាយពាណិជ្ជកម្ម ជាពិសេសការស្ទួនមុខងាររវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អចលនទ្រព្យនិងបញ្ចាំ មូលបត្ររដ្ឋ បរធនបាលកិច្ច) និងក្រសួង ស្ថាប័នដទៃទៀតជាដើម។
- ច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យពាណិជ្ជកម្ម មានចំនួនច្រើន ដែលមួយចំនួនមានភាពមិនស៊ីចង្វាក់គ្នា អស្តិភាព ពិបាកស្វែងរង/ស្វែងយល់ និងមិនអាចអនុវត្តបាន ដូចជា ច្បាប់ស្តីពីក្ស័យធន់ជាដើម។
- ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត មានភាពមិនច្បាស់លាស់ខាងផ្នែកខ្លឹមសារនៃបទដ្ឋានគតិយុត្តស្មុគស្មាញទាំងនីតិវិធីអនុវត្ត និងពាក្យពេចន៍នាំឱ្យពិបាកក្នុងការបកស្រាយខុសៗគ្នា ដែលបង្កជាការលំបាកដល់ពាណិជ្ជករ អ្នកវិនិយោគ មេធាវី ចៅក្រម ជាដើម។
- ច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន នៅមានគម្លាតជាមួយនឹងគោលនយោបាយថ្មីៗរបស់រាជរដ្ឋាភិបាល ជាពិសេសគឺការរីកចម្រើននៃបច្ចេកវិទ្យាឌីជីថល(Digitalization) និងបញ្ញាសិប្បនិម្មិត (AI)។ បញ្ហានេះតម្រូវឱ្យមានការសិក្សា ការធ្វើបច្ចុប្បន្នភាព និងការរៀបចំបទដ្ឋានគតិយុត្តដើម្បីឆ្លុះបញ្ចាំងពីទិដ្ឋភាពជាក់ស្តែង លើកស្ទួយវិស័យពាណិជ្ជកម្មក្នុងស្រុក ជំរុញសេដ្ឋកិច្ចឌីជីថលប្រកបដោយបរិយាបន្ន និងដើម្បីត្រៀមខ្លួនឱ្យបានរួចរាល់ក្នុងការចាកចេញពីប្រទេសអភិវឌ្ឍន៍តិចតួចនៅឆ្នាំ២០២៩
- រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើន ដើម្បីលើកស្ទួយវិស័យពាណិជ្ជកម្ម និងវិនិយោគ ដូចជាគោលនយោបាយជាតិស្តីពីហេដ្ឋារចនាសម្ព័ន្ធប្រកបដោយគុណភាព ព្រមទាំងពង្រឹងប្រព័ន្ធគុណភាពហេដ្ឋារចនាសម្ព័ន្ធគ្រប់វិស័យ យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា និងជាពិសេសការលើកទឹកចិត្ត និងជំរុញសកម្មភាពក្នុងការតភ្ជាប់គ្នារវាងពាណិជ្ជកម្ម ធុរកិច្ច និងការវិនិយោគ។ ក្នុងន័យនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនគួរចាំបាច់សិក្សា រៀបចំបន្ថែមដូចជា វិធានដោះស្រាយវិវាទក្នុងវិស័យពាណិជ្ជកម្ម (ច្បាប់ស្តីពីសន្ទានការី ការបង្កើតតុលាការពាណិជ្ជកម្ម ការទទួលយកកិច្ចសន្យាផ្សះផ្សាអន្តរជាតិ វិវាទច្បាប់(Conflict of laws) និងវិធានពាក់ព័ន្ធនឹងការលើកទឹកចិត្តតាមរយៈគោលនយោបាយពន្ធ គយជាដើម។ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនដូចជា វិធានដោះស្រាយវិវាទក្នុងវិស័យពាណិជ្ជកម្ម (ច្បាប់ស្តីពីសន្ទានការី ការបង្កើតតុលាការពាណិជ្ជកម្ម ការទទួលយកកិច្ចសន្យាផ្សះផ្សាអន្តរជាតិ) វិវាទ

ច្បាប់ ( Conflict of laws ) និងវិធានពាក់ព័ន្ធនឹងការលើកទឹកចិត្តតាមរយៈគោលនយោបាយពន្ធ គយ ជាដើម មិនទាន់បានរៀបចំនៅឡើយ ដែលបង្អាក់ការវិនិយោគពីបរទេស និងជាបញ្ហាអន្តរវិស័យ។

- យន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃទាំងក្នុងក្របខ័ណ្ឌនៃការតាក់តែង ការបកស្រាយ និង ការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យពាណិជ្ជកម្ម នៅមិនទាន់មានគោលការណ៍ និងអភិក្រមការងារច្បាស់លាស់ ដែលសុទ្ធសឹងជាឧបសគ្គរបស់អាជីវករ ធុរជន វិនិយោគិន និង រាំងស្ទះដល់ការរីកចម្រើនក្នុងវិស័យពាណិជ្ជកម្ម។

ក្នុងដំណើរការដោះស្រាយបញ្ហាប្រឈម និងដាក់ទិសដៅការងារបន្តក្នុងការលើកស្ទួយវិស័យ ពាណិជ្ជកម្ម ក្នុងគ្រាលំបាកនេះ **អគ្គលេខាធិការដ្ឋាន គ.ក.ច.** បានរៀបចំនូវកម្រងសំណួរមួយចំនួន សម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធចំណុះអង្គការនីតិប្រតិបត្តិ ស្ថាប័នតុលាការ ស្ថាប័នឯកជន ដៃគូ អភិវឌ្ឍនិងអ្នកជំនាញជាតិ អន្តរជាតិ រួមគ្នាស្វែងរកនូវចម្លើយ ដូចខាងក្រោមៈ

១. តើអ្វីជានីតិពាណិជ្ជកម្មសម្រាប់កម្ពុជា? តើវិស័យពាណិជ្ជកម្ម គ្រប់ដណ្តប់លើអ្វីខ្លះ? តើវិស័យ ពាណិជ្ជកម្ម មានទិសដៅផ្តោះទៅណា?

២. តើមានបញ្ហាប្រឈមអ្វីខ្លះ (ការប្រើប្រាស់ពាក្យពេចន៍ ខ្លឹមសារ ការបកស្រាយច្បាប់) ក្នុងការ អនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានក្នុងវិស័យពាណិជ្ជកម្ម? ក្នុងនាមជាស្ថាប័ន រាជរដ្ឋាភិបាល? ក្នុងនាមជាស្ថាប័នតុលាការ? ស្ថាប័នឯកជន?

៣. តើគួរកែតម្រង់ និងកែទម្រង់អ្វីខ្លះ ដើម្បីជំរុញការអភិវឌ្ឍវិស័យពាណិជ្ជកម្មកម្ពុជា? ការ សម្រួលដល់ពាណិជ្ជករ? ការលើកស្ទួយកម្រិតជីវភាពប្រជាពលរដ្ឋ? ការត្រៀមខ្លួនចេញពី ប្រទេសអភិវឌ្ឍន៍តិចតួច? ស្របតាមនិយាមអន្តរជាតិ?

៤. តើនៅក្នុងវិស័យពាណិជ្ជកម្ម មានច្បាប់និងលិខិតបទដ្ឋានគតិយុត្តណាខ្លះមិនអាចអនុវត្ត បាន? មូលហេតុ?

៥. តើនៅក្នុងវិស័យពាណិជ្ជកម្ម គួរតម្រូវឱ្យមានច្បាប់និងលិខិតបទដ្ឋានគតិយុត្តបន្ថែមផ្សេងទៀត ឬទេ? អ្វីខ្លះ? មូលហេតុ?

៦. តើអ្វីជាកត្តាជំរុញ គួរបង្កើតឱ្យមានក្រមពាណិជ្ជកម្មនៅកម្ពុជា? តើបញ្ហា និងតម្រូវការទាំង នោះ ឆ្លើយតបក្នុងទម្រង់បែបណា ចំពោះប្រទេសដែលប្រើប្រាស់ក្រមពាណិជ្ជកម្ម?

៧. តើក្រមពាណិជ្ជកម្មកម្ពុជានឹងផ្តល់អត្ថប្រយោជន៍អ្វីខ្លះសម្រាប់រាជរដ្ឋាភិបាល ស្ថាប័នឯកជន ការវិនិយោគ និងជីវភាពប្រជាពលរដ្ឋ? តើគួរកំណត់ជាតុផ្សំអ្វីខ្លះ អំពីនីតិពាណិជ្ជកម្មសម្រាប់ កម្ពុជា?

៨. ផ្អែកតាមវិសាលភាពនៃការប្រមូលចងក្រងច្បាប់ តើក្រមពាណិជ្ជកម្មកម្ពុជាគួរគ្របដណ្តប់លើ ទិដ្ឋភាពអ្វីខ្លះ? តើច្បាប់និងលិខិតបទដ្ឋានគតិយុត្តអ្វីខ្លះគួរតែរួមបញ្ចូលទៅក្នុងក្រមពាណិជ្ជកម្ម?

៩. តើក្រុមពាណិជ្ជកម្មគួរធ្វើឡើងក្រោមទម្រង់បែបណា ? តើមាតិការួមនៃក្រុមពាណិជ្ជកម្មគួរវិលេចលើទិដ្ឋភាពណាខ្លះ ?

១០.តើក្រុមពាណិជ្ជកម្មគួរតែត្រូវរៀបចំជាក្រុមដាច់ចេញពីនីតិវិធីអនុវត្ត ឬនីតិវិធីនៃការដោះស្រាយវិវាទដោយតុលាការពាណិជ្ជកម្មស្ថិតនៅក្នុងក្រមតែមួយ ?

១១.តើគោលការណ៍ទូទៅនៃក្រុមពាណិជ្ជកម្មគួរតែផ្តោតសំខាន់ទៅលើអ្វីខ្លះ ?

១២.នៅពេលក្រុមពាណិជ្ជកម្មចូលជាធរមាន តើច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ត្រូវវិសោធនកម្មទាំងអស់ឬយ៉ាងណា ?

## ១.៣ គោលបំណង និងលទ្ធផលរំពឹងទុក

នីតិរដ្ឋ ត្រូវពឹងផ្អែកលើគុណភាពនៃក្របខ័ណ្ឌច្បាប់។ ប្រទេសមួយ រឹងមាំ រីកចម្រើនអាស្រ័យលើប្រសិទ្ធភាពនៃការអនុវត្តច្បាប់។ ការរៀបចំក្រុមពាណិជ្ជកម្មសម្រាប់កម្ពុជា គឺជាការបោះជំហានថ្មីមួយ ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ក្នុងគោលបំណងធ្វើឱ្យច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យពាណិជ្ជកម្មមានឯកសណ្ឋាន និងសុខដុមគតិយុត្ត លើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តបទដ្ឋានគតិយុត្តក្នុងវិស័យពាណិជ្ជកម្ម រក្សាបាននូវគុណតម្លៃកម្ពុជា ក្នុងសកលភាវូបនីយកម្ម ប្រកបដោយរចនាសម្ព័ន្ធជាក់លាក់ តាមតក្កវិទ្យាគតិយុត្តមួយច្បាស់លាស់ ដើម្បីកាត់បន្ថយភាពស្មុគស្មាញ និងលុបបំបាត់ផលប៉ះពាល់អវិជ្ជមានលើវិស័យពាណិជ្ជកម្ម ក៏ដូចជាធានានូវ ស្តង់ដារភាពទាន់ពេលវេលា គុណភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងភាពជឿទុកចិត្តពីសំណាក់ពាណិជ្ជករ វិនិយោគិន និងធុរជន ជាពិសេសអ្នកទទួលផលចុងក្រោយ គឺប្រជាជនកម្ពុជា និងជាតិកម្ពុជាទាំងមូល។

ក្រុមពាណិជ្ជកម្មសម្រាប់កម្ពុជា នឹងត្រូវរៀបចំឡើងដើម្បីសម្រេចនូវលទ្ធផលរំពឹងទុក និងគុណប្រយោជន៍ជាក់លាក់ដូចខាងក្រោម៖

❖ **លទ្ធផលរំពឹងទុក**

- ✓ ធានានូវសុខដុមនីយកម្មនៃបទដ្ឋានគតិយុត្តក្នុងវិស័យពាណិជ្ជកម្មកម្ពុជា ទាំងសង្គតិភាព បូរណភាព នីត្យានុកូលភាព នៃការតាក់តែងសេចក្តីព្រាង និងការបកស្រាយសម្រាប់អនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត
- ✓ ធានានូវឯកសណ្ឋានូបនីយកម្មនៃបទដ្ឋានគតិយុត្ត ដែលបន្សុីគ្នារវាងគោលនយោបាយ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ក្នុងវិស័យពាណិជ្ជកម្ម
- ✓ មានគោលការណ៍ណែនាំច្បាស់លាស់ ងាយស្វែងរក ងាយស្វែងយល់ ងាយអនុវត្តសម្រាប់ប្រតិបត្តិការពាណិជ្ជកម្ម ស្របតាមបរិការណ៍កម្ពុជា និងឧត្តមានុវត្តន៍អន្តរជាតិ
- ✓ បង្កើនទំនុកចិត្តក្នុងការវិនិយោគ និងអាជីវកម្ម តាមរយៈក្របខ័ណ្ឌច្បាប់មួយច្បាស់លាស់តាមតក្កវិទ្យាគតិយុត្ត

- ✓ បង្កើនប្រសិទ្ធភាពនៃការដោះស្រាយវិវាទក្នុងវិស័យពាណិជ្ជកម្ម
- ✓ ជំរុញកំណើនសេដ្ឋកិច្ច តាមរយៈការវិនិយោគដោយមានទំនុកចិត្ត និងស្តង់ដារជាតិនិង អន្តរជាតិ
- ✓ បង្កើតយន្តការមួយច្បាស់លាស់សម្រាប់រាជរដ្ឋាភិបាលក្នុងការត្រួតពិនិត្យ និងវាយតម្លៃ គុណភាពនៃការតាក់តែង និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ក្នុងវិស័យពាណិជ្ជកម្ម ដោយទទួលខុសត្រូវដោយស្ថាប័នជាក់លាក់ នៃរាជរដ្ឋាភិបាល និងស្របតាមនីតិវិធីរដ្ឋបាលច្បាស់លាស់។

❖ **គុណប្រយោជន៍**

- ✓ ធ្វើឱ្យមានឯកសណ្ឋានូបនីយកម្មនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យពាណិជ្ជកម្ម ទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន និងវិធានថ្មីៗតម្រូវបន្ថែមទៀត
- ✓ ធ្វើឱ្យមានភាពច្បាស់លាស់ របៀបរៀបរយ សណ្តាប់ធ្នាប់ សន្តិសុខគតិយុត្ត លើការ តាក់តែង ការប្រឹក្សា ការអនុម័ត ការអនុវត្ត ការបកស្រាយ និងការដោះស្រាយវិវាទក្នុង វិស័យពាណិជ្ជកម្ម
- ✓ ធ្វើឱ្យសាមញ្ញ ងាយស្វែងរក ងាយយល់ ងាយអនុវត្ត តែស្របតាមតក្កវិទ្យាគតិយុត្តជា ស្តង់ដាអន្តរជាតិ
- ✓ ចូលរួមកាត់បន្ថយការជាន់សមត្ថកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងវិស័យពាណិជ្ជកម្ម
- ✓ ការពង្រឹងនិងពង្រីក ក្របខ័ណ្ឌគតិយុត្តក្នុងវិស័យពាណិជ្ជកម្ម នឹងបង្កើតបានបរិយាកាស ធុរកិច្ចកាន់តែងាយស្រួលសម្រាប់ការវិនិយោគ លើកកម្ពស់អាជីវកម្មឱ្យកាន់តែមាន សមត្ថភាពប្រកួតប្រជែងខ្ពស់ និងបន្ធូរបន្ថយរបាំងពាណិជ្ជកម្មដើម្បីសម្រេចបាន កំណើនកាន់តែខ្ពស់ ប្រកបដោយបរិយាបន្ន និងមានចីរភាព ដើម្បីលើកកម្ពស់ជីវភាព រស់នៅ និងមុខរបររបស់ប្រជាពលរដ្ឋ
- ✓ ផ្តល់នូវអត្ថប្រយោជន៍សម្រាប់ការកសាងធនធានមនុស្សក្នុងវិស័យច្បាប់ ទាំងចៅក្រម មេធាវី អ្នកជំនាញច្បាប់ និស្សិតច្បាប់ ពាក់ព័ន្ធនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុង វិស័យពាណិជ្ជកម្ម។

## ១.៤ វិសាលភាព ដែនកំណត់ និងអភិក្រម

❖ **វិសាលភាព**

ការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា នឹងសិក្សាពីវដ្តពាណិជ្ជកម្ម ការរៀបចំក្នុងកម្រិតនៃ ការបែងចែកប្រភេទអាជីវកម្ម ទម្រង់អាជីវកម្ម ទំនាក់ទំនងអាជីវកម្ម វិធានពាណិជ្ជកម្ម ការគ្រប់គ្រង ប្រតិបត្តិការអាជីវកម្ម ការជម្រះបញ្ជី រំលាយនិងក្ស័យធន និងការដោះស្រាយវិវាទក្នុងវិស័យពាណិជ្ជកម្ម។

❖ **ដែនកំណត់**

ការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា នឹងផ្តោតលើទិដ្ឋភាពច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ក្នុងវិស័យពាណិជ្ជកម្ម និងវិនិយោគ ចាប់តាំងពីឆ្នាំ១៩៩៣ ដល់បច្ចុប្បន្ន ជាមួយនឹងបញ្ហាប្រឈមដែលបានកើតឡើងជាក់ស្តែងកន្លងមកតាមរយៈក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ ស្ថានភាពបច្ចុប្បន្ន និងការប្រមើលមើលនូវតម្រូវការតាក់តែងច្បាប់និងលិខិតបទដ្ឋានគតិយុត្តថ្មីបន្ថែមទៀត សម្រាប់ដោះស្រាយបញ្ហាចំពោះមុខផង ការចូលជាសមាជិកកិច្ចព្រមព្រៀងពាណិជ្ជកម្មថ្មីផ្សេងទៀតផង និងដើម្បីត្រៀមចាកចេញដោយរលូន ពីចំណាត់ថ្នាក់ប្រទេសមានការអភិវឌ្ឍតិចតួច ដែលមានគោលដៅកាត់បន្ថយ ឬលុបបំបាត់ផលប៉ះពាល់អវិជ្ជមានដែលកើតចេញពីការបាត់បង់ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងវិធានការជំនួយអន្តរជាតិនានា ក៏ដូចជា ការធានាបាននូវចីរភាពនៃការអភិវឌ្ឍក្រោយការចាកចេញនៅឆ្នាំ២០២៩។

❖ **អភិក្រម**

ការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា នឹងរៀបចំឡើងដោយប្រកាន់អភិក្រម ដូចខាងក្រោម៖

- ✓ សិក្សាលើមូលដ្ឋាននៃបញ្ហា សំដៅដល់ការស្វែងយល់ពីចំណោទនៃបញ្ហាបច្ចុប្បន្ន ដែលកើតចេញពីការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ជះឥទ្ធិពលលើអាជីវកម្ម វិនិយោគ និងវិភាគលើចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង សម្រាប់ថ្ងៃអនាគត
- ✓ សិក្សា ប្រៀបធៀប វិភាគ កំណត់នូវនិយមន័យច្បាស់លាស់សម្រាប់នីតិពាណិជ្ជកម្មកម្ពុជា ដោយធានាសង្គតិភាពនឹងក្រមរដ្ឋប្បវេណី នីតិការងារ នីតិសាធារណៈ (ពន្ធដារ គយ) ជាដើម
- ✓ សិក្សាអំពីការប្រែប្រួលនៃរបត់នយោបាយពិភពលោក ជម្លោះពាណិជ្ជកម្មរវាងមហាអំណាចនិងក្នុងតំបន់ ជម្លោះព្រំដែន និងការរីកចម្រើនខាងបច្ចេកវិទ្យាព័ត៌មានវិទ្យា បញ្ញាសិប្បនិម្មិត (AI) ដែលជះឥទ្ធិពលលើវិស័យពាណិជ្ជកម្មសកល ជាពិសេសកម្ពុជា ដើម្បីកំណត់ពីតម្រូវការបទដ្ឋានគតិយុត្តបន្ថែម
- ✓ សិក្សា ច្បាប់និងលិខិតបទដ្ឋានគតិយុត្តតាមលំដាប់លំដោយជាលក្ខណៈ ប្រមូលផ្តុំ (Consolidation) តាមឋានានុក្រម និងកាលប្បវត្តិ ទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលបាននិរាករណ៍ វិសោធនកម្ម និងមានជាធរមាន
- ✓ សិក្សា រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ជាលក្ខណៈ ចងក្រង (Compilation) តាមរយៈការប្រៀបធៀប បែងចែកតាមកម្មវត្ថុគតិយុត្ត កាលប្បវត្តិ និងផ្ទៀងផ្ទាត់ធរមាន

ប្បញ្ញត្តិ ដោយធានាឱ្យបាននូវគោលការណ៍ បូរណភាពនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្ថិតនៅជាធរមាន និងសង្គតិភាពនៃការរៀបចំមាតិកា

- ✓ រៀបចំវេទិកាពិគ្រោះយោបល់កម្រិតចង្អៀតនិងទូលាយជាមួយតួអង្គពាក់ព័ន្ធជាតិនិងអន្តរជាតិ ដើម្បីធានាថាការរៀបចំក្រមពាណិជ្ជកម្ម នឹងនាំមកនូវគុណប្រយោជន៍ដល់រាជរដ្ឋាភិបាល អាជីវករ វិនិយោគិន ដោយរក្សាបានភាពបត់បែនខ្ពស់ក្នុងការអនុវត្ត និងដោះស្រាយបាននូវបញ្ហាប្រឈមនានាទាំងនៅចំពោះមុខ និងនាពេលអនាគត
- ✓ បង្កើតក្រុមការងារ រៀបចំផែនការលម្អិត និងក្របខ័ណ្ឌពេលវេលាសមស្រប ជាមួយនឹងការបែងចែកតួនាទី ភារកិច្ចច្បាស់លាស់ សម្រាប់ការទទួលបន្ទុកកិច្ចការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា ជាអន្តរស្ថាប័ន ក្នុងជវភាពនៃប្រព័ន្ធតួអង្គតែមួយ។

## ២. វិធីសាស្ត្រក្នុងការរៀបចំក្រម

### ២.១ វិធីសាស្ត្រនៃការរៀបចំក្រម- ឧត្តមានុវត្តន៍អន្តរជាតិ

ជាគោលការណ៍ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ត្រូវគ្រោងរៀបចំដោយផ្អែកលើការចាំបាច់ចំនួន ៣ គឺ៖

ទី១. ការកំណត់ដោយក្របខ័ណ្ឌគតិយុត្តជាធរមាន៖ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនីមួយៗត្រូវបង្កើតឡើងដោយអនុលោមតាមការចង្អុលបង្ហាញជាក់លាក់ ឬដោយពុំជាក់លាក់ ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលមានឋានានុក្រមស្មើ ឬខ្ពស់ជាង។

ទី២. ទិសដៅនៃការកែទម្រង់ និងគោលនយោបាយ៖ ក្របខ័ណ្ឌកែទម្រង់និងគោលនយោបាយអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព គឺចាំបាច់ត្រូវរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តថ្មី ឬវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដែលមានតម្លៃទាំងការណែនាំ ទាំងការចាប់បង្ខំ។

ទី៣. ការវិវឌ្ឍសង្គម សេដ្ឋកិច្ចនិងតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល៖ ដើម្បីដោះស្រាយបញ្ហាដែលកើតឡើងក្នុងការវិវត្តនៃសង្គម ដោយមិនមានកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាជាធរមាន រាជរដ្ឋាភិបាលមានកាតព្វកិច្ចកែសម្រួល ឬរៀបចំលិខិតបទដ្ឋានគតិយុត្តថ្មី។

ការតាក់តែងក្រមគឺជាឧត្តមានុវត្តន៍អន្តរជាតិ ដែលប្រទេសប្រកាន់ប្រព័ន្ធច្បាប់ស៊ីវិល (Civil law system) បានសិក្សានិងកំណត់គោលការណ៍និងវិធីសាស្ត្រគតិយុត្ត ក្នុងការប្រមូលផ្តុំ និងចងក្រងលិខិតបទដ្ឋានគតិយុត្ត ផ្អែកតាមចំណាត់ថ្នាក់អត្ថបទ ប្រកបដោយរចនាសម្ព័ន្ធជាក់លាក់តាមតក្កវិជ្ជាគតិយុត្ត ដើម្បីសម្រេចបានជាកម្រងឯកសារមួយ ដែលមានមាតិការួមតែមួយ។ ការតាក់តែងក្រម មានវិធីសាស្ត្រចំនួន បី គឺ ការប្រមូលផ្តុំ (Consolidation) ការចងក្រង (Compilation) និងក្រម (Codification)។

### ២.១.១ ការប្រមូលផ្តុំ ការចងក្រង និងក្រម

វិធីសាស្ត្រនៃការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ក្នុងវិស័យតែមួយឱ្យស្ថិតក្នុងឯកសារតែមួយ មានសង្គតិភាព មានឯកសណ្ឋាននិងសុខដុមនីយកម្មនៃបទប្បញ្ញត្តិគតិយុត្តជាធរមាន គឺមិនមានគោលការណ៍ណែនាំរួមជាស្តង់ដារអន្តរជាតិនោះទេ ពោលគឺអាស្រ័យទៅលើបរិបទរបស់ប្រទេស ការជះឥទ្ធិពលពីប្រព័ន្ធច្បាប់មួយមកលើច្បាប់នៃប្រទេសមួយផ្សេងទៀត ឬកើតចេញពីការសិក្សាជាបទពិសោធន៍ (Best practice) ពីគ្នាទៅវិញទៅមក។

ជារួម វិធីសាស្ត្រនេះ ត្រូវបានមើលឃើញ ក្នុងរូបភាពចំនួន បីគឺ ការប្រមូលផ្តុំ ការចងក្រង និងក្រម ដោយត្រូវបានកំណត់និយមន័យ និងវិធីសាស្ត្ររៀបចំដាច់ដោយឡែកពីគ្នា ប៉ុន្តែប្រទាក់ក្រឡាគ្នាជាជំហាន។ ចំពោះតម្រូវការធនធានទាំងធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងក្របខ័ណ្ឌពេលវេលា ត្រូវយកចិត្តទុកដាក់សិក្សាឱ្យបានជាក់លាក់ ទៅតាមបរិបទនៃប្រទេសនីមួយៗនិងតម្រូវការជាក់ស្តែង។ ក្នុងន័យនេះ តារាងខាងក្រោមត្រូវបានសិក្សារៀបចំឡើង ក្នុងគោលបំណងប្រៀបធៀបពីលក្ខណៈខុសគ្នា និងអាចយកជាមូលដ្ឋាននៃការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យឱ្យស្ថិតក្នុងឯកសារតែមួយ និងមានឯកសណ្ឋានគតិយុត្ត ទៅថ្ងៃអនាគត។

| ប្រភេទ | និយមន័យ | វិធីសាស្ត្ររៀបចំ | ធនធានមនុស្ស[9] | ហិរញ្ញវត្ថុ[10] | ពេលវេលា[11] | ករណីសិក្សា |
|---|---|---|---|---|---|---|
| **ការប្រមូលផ្តុំ** | ការប្រមូលផ្តុំ គឺជាការប្រមូលចងក្រង និងប្រមូលផ្តុំបទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយបង្ហាញនិង/ឬបញ្ចូលនូវលិខិតបទដ្ឋានគតិយុត្តដែលវិសោធនកម្ម និងលិខិតបទដ្ឋានគតិយុត្តនិរាករណ៍ ដោយពុំកែប្រែខ្លឹមសារឡើយ ដើម្បីធានាឱ្យបាននូវ | ១.កំណត់ប្រធានបទ និងមុខសញ្ញាកម្រិតច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ<br>២. ប្រមូលច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទាំងអស់ តាមរ | តម្រូវការធនធានមនុស្សក្នុងរង្វង់ ១០ ទៅ ១៥រូប៖<br>- អ្នកច្បាប់ឬមន្ត្រីនីតិកម្មយ៉ាងតិចចំនួន ៨ទៅ១០រូប ដើម្បីប្រមូល | ថវិកាយ៉ាងតិច៖ ១០,០០០ USD<br>- ថវិកាសម្រាប់កិច្ចប្រជុំ | យ៉ាងតិច ២ ទៅ ៤ខែ | KH: ការប្រមូលច្បាប់និងលិខិតបទដ្ឋានគតិយុត្ត នៅក្នុងគេហទំព័ររបស់ក្រសួង ស្ថាប័នសាមី |

[9] ឧទាហរណ៍ដើម្បីប្រៀបធៀបលក្ខណៈខុសគ្នា និងទាមទារឱ្យមានការសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធ

[10] សាកល្បងគណនាដើម្បីប្រៀបធៀបលក្ខណៈខុសគ្នា

[11] សាកល្បងកំណត់ដើម្បីប្រៀបធៀបលក្ខណៈខុសគ្នា

| ប្រភេទ | និយមន័យ | វិធីសាស្ត្ររៀបចំ | ធនធានមនុស្ស[9] | ហិរញ្ញវត្ថុ[10] | ពេលវេលា[11] | ករណីសិក្សា |
|---|---|---|---|---|---|---|
| | គោលការណ៍ពិនិត្យានុកូលភាព ពោលគឺ ដើម្បីសម្រួលដល់ការស្វែងរកនិងស្វែងយល់ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។ | យៈកិច្ចសហការជាមួយ ក.ក.ច. នៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ<br>៣.ដាក់បញ្ចូលច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងអត្ថបទច្បាប់តែមួយ (Only technical editing allowed)<br>៤.ដាក់ជូនថ្នាក់ដឹកនាំក្រសួង ស្ថាប័នពិនិត្យនិងសម្រេច<br>៥.បោះពុម្ព និងផ្សព្វផ្សាយជាសាធារណៈ តាមរយៈសេចក្តីសម្រេចឬប្រកាសរបស់ប្រធានក្រសួង ស្ថាប័ន | - អ្នកច្បាប់ឬមន្ត្រីនីតិកម្ម យ៉ាងតិចចំនួន ២ទៅ៣ នាក់សម្រាប់ដាក់បញ្ចូលជាអត្ថបទតែមួយ<br>- មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុជាជំនួយគាំទ្រ<br>- ការចូលរួមពីភាគីផ្សេងៗតាមការចាំបាច់ | - ថវិកាសម្រាប់ចងក្រង<br>- ថវិកាសម្រាប់លើកទឹកចិត្ត (បន្ថែមពីប្រាក់បៀវត្សន៍) | | UK: Companies Act 2006<br>FR: Labor Code |
| **ការចងក្រង** | ការចងក្រងគឺជា ការប្រមូលផ្តុំអត្ថបទច្បាប់និងលិខិតបទដ្ឋានគតិយុត្តដាក់តាមលំដាប់លំដោយ ដែលរៀបចំតាមកម្មវត្ថុគតិយុត្ត កាលប្បវត្ត និងផ្ទៀងផ្ទាត់បទប្បញ្ញត្តិជាធរមាន ដោយអាចកែសម្រួលខ្លឹមសារ និងទម្រង់តិចតួច។ ការចងក្រងធ្វើឡើងដើម្បី | ១.កំណត់ប្រធានបទ និងមុខសញ្ញា កម្រិតច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ<br>២. ប្រមូលច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទាំងអស់ តាមរយៈកិច្ចសហការ | តម្រូវការធនធានមនុស្សក្នុងរង្វង់ ២០ ទៅ ២៥រូប៖<br>- អ្នកច្បាប់ឬមន្ត្រីនីតិកម្ម យ៉ាងតិចចំនួន ៨ទៅ១០ រូប ដើម្បីប្រមូល | ថវិកាយ៉ាងតិច៖ ២៥,០០០ USD<br>- ថវិកាសម្រាប់កិច្ចប្រជុំ៖<br>- ថវិកាសម្រាប់ចងក្រង ៖ | យ៉ាងតិច ៣ ទៅ៦ ខែ | KH: កម្រងសម្រង់បទប្បញ្ញត្តិច្បាប់សំខាន់ៗទាក់ទងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>UK: UK Statute Books |

| ប្រភេទ | និយមន័យ | វិធីសាស្ត្ររៀបចំ | ធនធានមនុស្ស[9] | ហិរញ្ញវត្ថុ[10] | ពេល[11] វេលា | ករណីសិក្សា |
|---|---|---|---|---|---|---|
| | ជានាឱ្យបាននូវគោលការណ៍ បូរណភាពនៃលិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមាន និងសង្គតិភាពនៃការរៀបចំមាតិកា។ | ជាមួយ ក.ក.ច. នៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ<br>៣. រៀបចំតាមចំណាត់ថ្នាក់គតិយុត្ត (Chronologically Or Thematically) ជាមាតិកា<br>៤. ដាក់បញ្ចូលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទៅតាមមាតិកាដែលបានកំណត់<br>៥.ដាក់ជូនថ្នាក់ដឹកនាំក្រសួង ស្ថាប័នពិនិត្យនិងសម្រេច<br>៦. បោះពុម្ព និងផ្សព្វផ្សាយជាសាធារណៈ តាមរយៈសេចក្ដីសម្រេចឬប្រកាសរបស់ប្រធានក្រសួង ស្ថាប័ន | - អ្នកច្បាប់ឬមន្ត្រីនីតិកម្មចំនួន ២ទៅ៣រូប ដើម្បីសម្រង់យកច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន<br>- អ្នកច្បាប់ឬមន្ត្រីនីតិកម្មចំនួន ២ទៅ៣នាក់ សម្រាប់រៀបចំមាតិកាតាមចំណាត់ថ្នាក់គតិយុត្ត<br>- អ្នកច្បាប់ឬមន្ត្រីនីតិកម្មយ៉ាងតិចចំនួន ៥នាក់ ដាក់បញ្ចូលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទៅតាមមាតិកាដែលបានកំណត់<br>- មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុជាជំនួយគាំទ្រ<br>- ការចូលរួមពីភាគីផ្សេងៗតាមការចាំបាច់ | | | FR: Local customs |

| ប្រភេទ | និយមន័យ | វិធីសាស្ត្ររៀបចំ | ធនធានមនុស្ស[9] | ហិរញ្ញវត្ថុ[10] | ពេលវេលា[11] | ករណីសិក្សា |
|---|---|---|---|---|---|---|
| ក្រម | ក្រម គឺជាការប្រមូល ចងក្រង រៀបចំឡើងវិញនូវបទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននានា ទាំងកម្រិតច្បាប់ និងកម្រិតឯកសារអនុវត្តប្រកបដោយរចនាសម្ព័ន្ធជាក់លាក់តាមតក្កវិជ្ជាគតិយុត្តមួយច្បាស់លាស់ និងក្នុងវិស័យជាក់លាក់ ដើម្បីសម្រេចបានឯកសារគតិយុត្តមួយ ដែលមានមាតិការួម និងមានអានុភាពគតិយុត្ត។ | ១. កំណត់ប្រធានបទ និងមុខសញ្ញា កម្រិតច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ<br>២. ប្រមូលច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទាំងអស់ តាមរយៈកិច្ចសហការជាមួយ ក.ក.ច. នៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ<br>៣. បែងចែក ច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលបាននិរាករណ៍ វិសោធនកម្ម ឬជាធរមាន<br>៤. វិភាគ និងវាយតម្លៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (កំណត់ចន្លោះខ្វះខាត វិវាទគតិយុត្ត ឬផុតអាយុកាល)<br>៥. រៀបចំរចនាសម្ព័ន្ធមាតិកា (គន្ថី ជំពូក ផ្នែក មាត្រា) | តម្រូវការធនធានមនុស្ស (កម្រិតខ្ពស់) ចន្លោះពី ២០ ទៅ៥០រូបមកពីអន្តរក្រសួង ស្ថាប័ន៖<br>- អ្នកច្បាប់ឬមន្ត្រីនីតិកម្មយ៉ាងតិច ចំនួន ៨ទៅ១០ រូប ដើម្បីប្រមូល<br>- អ្នកច្បាប់ឬមន្ត្រីនីតិកម្មយ៉ាងតិច ចំនួន ២ទៅ៣ រូប ដើម្បីសម្រង់យកច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន<br>- អ្នកច្បាប់ឬមន្ត្រីនីតិកម្មយ៉ាងតិចចំនួន ៥ទៅ១០ រូប មកពីអន្តរស្ថាប័ន ដើម្បី វិភាគនិងវាយតម្លៃ<br>- អ្នកច្បាប់ឬមន្ត្រីនីតិកម្មចំនួន ២ទៅ៣នាក់ | ថវិកាយ៉ាងតិច៖ ២០០,០០០USD ឬលើសនេះ៖<br>- ថវិកាសម្រាប់កិច្ចប្រជុំ៖<br>- ថវិកាសម្រាប់សិក្ខាសាលា៖<br>- ថវិកាសម្រាប់លើកទឹកចិត្ត៖ | យ៉ាងតិច ៣ឆ្នាំ | KH: ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមបរិស្ថាន<br>UK: Sale of Goods Act 1979<br>FR: Commercial Code |

| ប្រភេទ | និយមន័យ | វិធីសាស្ត្ររៀបចំ | ធនធានមនុស្ស[9] | ហិរញ្ញវត្ថុ[10] | ពេល[11] វេលា | ករណីសិក្សា |
|---|---|---|---|---|---|---|
| | | ៦. រៀបចំលេខកូដ កំណត់ប្រភេទច្បាប់ ឬអនុក្រឹត្យ ឬប្រកាស (L, R, D)<br>៧. សរសេរឡើងវិញក្នុងទម្រង់ជាអត្ថបទច្បាប់<br>៨. ប្រឹក្សាយោបល់ជាមួយភាគីពាក់ព័ន្ធ កែសម្រួល ឬបំពេញបន្ថែម<br>៩. បំពេញតាមនីតិវិធីធ្វើច្បាប់ (ក្រុមប្រឹក្សាអ្នកច្បាប់ គណៈរដ្ឋមន្ត្រី គណៈកម្មការជំនាញនៃរដ្ឋសភា គណៈកម្មការជំនាញ នៃព្រឹទ្ធសភា កិច្ចប្រជុំអនុម័ត)<br>១០. ឡាយព្រះហស្ថលេខាពីព្រះមហាក្សត្រប្រកាសឱ្យប្រើ និងផ្សព្វផ្សាយជាសាធារណៈ។ | សម្រាប់រៀបចំមាតិកាតាមតក្កវិទ្យាគតិយុត្ត<br>- អ្នកច្បាប់ឬមន្ត្រីនីតិកម្ម អ្នកបច្ចេកទេសcode ចំនួន ៣ ទៅ៥ រូប សម្រាប់កំណត់ប្រភេទលិខិតបទដ្ឋាន<br>- អ្នកច្បាប់ឬមន្ត្រីនីតិកម្ម ចំនួន ១០ ទៅ២០រូប មកពីអន្តរស្ថាប័ន សរសេរខ្លឹមសារឡើងវិញ តាមមាតិកា<br>- អ្នកច្បាប់ឬមន្ត្រីនីតិកម្មរួមគ្នាពិនិត្យលើអនុលោមភាព និងភាពគ្រប់ជ្រុងជ្រោយ<br>- អ្នកច្បាប់ឬមន្ត្រីនីតិកម្ម ២ ទៅ៣នាក់ ជាមន្ត្រីបង្គោលសម្របសម្រួល បូកសរុប និងរបាយការណ៍ | | | |

| ប្រភេទ | និយមន័យ | វិធីសាស្ត្ររៀបចំ | ធនធានមនុស្ស[9] | ហិរញ្ញវត្ថុ[10] | ពេល[11] វេលា | ករណីសិក្សា |
|---|---|---|---|---|---|---|
| | | | - មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុជាជំនួយគាំទ្រ<br>- ការចូលរួមពីភាគីផ្សេងៗតាមការចាំបាច់ | | | |

## ២.១.២. យន្តការស្ថាប័ននៃការរៀបចំក្រម

ការរៀបចំក្រម គឺមានវិធីសាស្ត្រផ្សេងៗគ្នា ទៅតាមបរិបទនៃប្រទេស ដោយមិនមានគោលការណ៍ណែនាំរួមណាមួយកំណត់ជាក់លាក់នោះទេ។ ជាក់ស្តែង ប្រទេសបារាំង ជាប្រទេសដែលរៀបចំបានក្រម រហូតដល់ទៅ៧៧ក្រម ដោយមូលហេតុចម្បងគឺរាជរដ្ឋាភិបាលបារាំងបានបង្កើតនូវយន្តការស្ថាប័ន (គណៈកម្មការជាន់ខ្ពស់ក្រមនីយកម្មបារាំង និងវិធីសាស្ត្រច្បាស់លាស់ (ក្រមនីយកម្មនីតិស្ថិរភាព និងក្រមនីយកម្មនីតិសារជាតុ)។ បន្ថែមពីនេះ ចំណុចពិសេសនៃក្រមរបស់ប្រទេសបារាំងគឺការកំណត់លេខមាត្រា ដោយក្នុងនោះ មាត្រាដែលផ្តើមដោយអក្សរ L សំដៅលើបទដ្ឋាននីតិបញ្ញត្តិ និងមានលេខ ៣ខ្ទង់បន្ទាប់សំដៅដល់គន្ថី មាតិកា និងជំពូក រីឯមាត្រាផ្តើមដោយអក្សរ R សំដៅលើបទដ្ឋាននីតិប្រតិបត្តិ។

រីឯ ប្រទេសអាល្លឺម៉ង់ ជាប្រទេសមួយដែលរៀបចំក្រមតាមរយៈការបង្កើតក្រុមការងារបច្ចេកទេសគន្លឹះ ដឹកនាំដោយក្រសួងមួយជាក់លាក់ ដោយទទួលបានការចាត់តាំងពីរដ្ឋាភិបាល ដើម្បីរៀបចំគម្រោង ទស្សនាទាន វិធីសាស្ត្រ ផែនការសកម្មភាព និងដំណើរការរៀបចំក្រម។ គណៈកម្មការជំនាញចំពោះកិច្ចដែលមានសមាសភាពពីក្រសួងស្ថាប័ន វិស័យឯកជន និងតួអង្គពាក់ព័ន្ធ ត្រូវបានបង្កើតឡើងសម្រាប់ត្រួតពិនិត្យ តាមដាន លើវឌ្ឍនភាពការងាររបស់ក្រុមការងារបច្ចេកទេសគន្លឹះ។ សេចក្តីព្រាងក្រមត្រូវបានដាក់ឆ្លងគណៈរដ្ឋមន្ត្រី ពិនិត្យ ផ្តល់យោបល់ និងសម្រេចលើសេចក្តីព្រាង មុននឹងបន្តនីតិវិធីទៅសភា និងឆ្លងកាត់ការត្រួតពិនិត្យធម្មនុញ្ញភាពមុននឹងប្រកាសដាក់ឱ្យអនុវត្ត។

ប្រទេសហ្វីលីពីន ជាប្រទេសមួយដែលមានប្រព័ន្ធច្បាប់ចម្រុះ ដោយរងឥទ្ធិពលពីប្រព័ន្ធច្បាប់ស៊ីវិលរបស់ប្រទេសអេស្ប៉ាញផង និងប្រព័ន្ធច្បាប់ Common Law ពីសហរដ្ឋអាមេរិកផង។ ប្រទេសហ្វីលីពីន មានក្រមលើសពីចំនួន ១០ក្រម ដូចជាក្រមរដ្ឋប្បវេណី ក្រមគ្រួសារ ក្រមការងារ ក្រមពន្ធដារ ក្រមរដ្ឋបាល ក្រមពាណិជ្ជកម្មជាដើម។ វិធីសាស្ត្រនៃការរៀបចំក្រមច្បាប់នៅប្រទេសហ្វីលីពីន គឺផ្អែកលើការប្រមូលផ្តុំ (អាចកែប្រែ ឬបញ្ចូលគ្នា) និងរៀបចំច្បាប់ដែលមានទំនាក់ទំនងគ្នាឱ្យស្ថិតក្នុងក្រម ឬច្បាប់ឯកទេស ដើម្បីឱ្យមានភាពច្បាស់លាស់ និងងាយស្រួលអនុវត្ត។ ការរៀបចំក្រម ចាប់ផ្តើមពីការកំណត់អំពីបញ្ហា តម្រូវការកែទម្រង់ច្បាប់ ការបង្កើតគណៈកម្មការឬក្រុមជំនាញអន្តរស្ថាប័នក្នុងរដ្ឋាភិបាល និងស្ថាប័នតុលាការដើម្បីរៀបចំសេចក្តីព្រាងក្រម ការពិគ្រោះយោបល់ជាសាធារណៈ ការពិនិត្យធម្មនុញ្ញភាពពីក្រសួងយុត្តិធម៌ និងការដាក់ឆ្លងសភាពិនិត្យ អនុម័ត មុននឹងការចុះហត្ថលេខាប្រកាសដាក់ឱ្យអនុវត្តដោយប្រធានាធិបតី។

### ២.១.៣ គុណប្រយោជន៍ និងគុណវិបត្តិ នៃការប្រមូលផ្តុំ ការចងក្រងក្រម

| ប្រភេទ | គុណប្រយោជន៍ | គុណវិបត្តិ | ជម្រើស |
|---|---|---|---|
| **ការប្រមូលផ្តុំ** | - វិធីសាស្ត្រសាមញ្ញ និងលឿន ដោយគ្រាន់តែប្រមូលច្បាប់និងលិខិតបទដ្ឋានទាំងអស់បញ្ចូលរួមគ្នា តាមរយៈកិច្ចសហការជាមួយ ក.ក.ច. នៅតាមក្រសួង ស្ថាប័ន<br>- ចំណាយធនធានតិច ទាំងធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងពេលវេលា<br>- ជំនួយដល់អ្នកច្បាប់ និស្សិតច្បាប់ សាធារណៈជន ងាយស្រួលស្វែងរក និងសិក្សាពីច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធទាំងអស់។ | - កំណត់ត្រួតស៊ីលើច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលអសង្គតិភាព ឬអសុពលភាព<br>- ជាន់ ឬស្ទួន ច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្រដៀងគ្នា<br>- គ្មានការរៀបចំជាលក្ខណៈប្រព័ន្ធបែបតក្កវិទ្យាគតិយុត្ត<br>- ច្រើនទំព័រ ឬច្រើនអត្ថបទពិបាកស្វែងរក បោះពុម្ព និងផ្សព្វផ្សាយ | មិនគួរជ្រើសរើសវិធីសាស្ត្រនេះ សម្រាប់ការប្រមូលច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ក្នុងប្រធានបទណាមួយឡើយ។ ប៉ុន្តែវិធីសាស្ត្រនេះអាចនឹងយកមកប្រើប្រាស់សម្រាប់ដំណាក់កាលដំបូងនៃការធ្វើក្រម។ |
| **ការចងក្រង** | - ការចំណាយធនធាន ទាំងធនធានមនុស្ស និងធនធានហិរញ្ញវត្ថុក្នុងកម្រិតមធ្យម | - ត្រូវការធនធានមនុស្ស ជាអ្នកច្បាប់មានជំនាញខ្ពស់ និងការសម្របសម្រួលពីក្រសួង ស្ថាប័នពាក់ព័ន្ធ | ជាបទពិសោធ ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានជ្រើសរើសវិធីសាស្ត្រសម្រាប់ប្រមូលចងក្រងនូវច្បាប់ និង |

| ប្រភេទ | គុណប្រយោជន៍ | គុណវិបត្តិ | ជម្រើស |
|---|---|---|---|
| | - ក្លាយជាឧបករណ៍គន្លឹះដែលមានបទប្បញ្ញត្តិជាធរមានជួយដល់អ្នកច្បាប់ មន្ត្រីរាជការ និស្សិតច្បាប់ ធុរជន ក្នុងការស្វែងរក ស្វែងយល់ និងជាឯកសារយោងសម្រាប់ការបំពេញភារកិច្ច និងការសិក្សា ពាក់ព័ន្ធនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន លើប្រធានបទដែលបានកំណត់<br>- ផ្តល់ភាពងាយស្រួលស្វែងរក និងចម្លងតាមមាតិកា ផ្នែក ឬចំណុចដែលចង់សិក្សា ពាក់ព័ន្ធនឹងវិស័យ ឬការងាររបស់ខ្លួន<br>- ធានាបាននូវគោលការណ៍បូរណភាពនៃលិខិតបទដ្ឋានគតិយុត្ត និងសង្គតិភាពនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលមានជាធរមាន | ដើម្បីកំណត់ធរមាននៃច្បាប់និងលិខិតបទដ្ឋាន គតិយុត្ត<br>- ត្រូវការអ្នកច្បាប់មានជំនាញខ្ពស់ ក្នុងវិស័យ ឬប្រធានបទជាក់លាក់ ដើម្បីរៀបចំមាតិកា<br>- ត្រូវការពេលវេលាពិនិត្យ បែងចែក និងសរសេរឡើងវិញក្នុងទម្រង់ជាអត្ថបទ<br>- កំហុសអក្ខរាវិរុទ្ធ និងឃ្លោងឃ្លាអាចខុសឆ្គងតិចតួចពីខ្លឹមសារដើម | ព្រះរាជក្រឹត្យសំខាន់ៗទាំងឡាយដែលស្ថិតនៅជាធរមាន ក្នុងដែនសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រកបដោយសាមញ្ញភាព បូរណភាព គុណភាព និងសោភ័ណភាព សម្រាប់ជាគុណប្រយោជន៍ដល់ការស្វែងយល់និងការប្រតិបត្តិការងារក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ |
| **ក្រម** | - អនុញ្ញាតឱ្យមានការកែប្រែបចនាសម្ព័ន្ធនៃអត្ថបទគតិយុត្ត និរាករណ៍ ឬរៀបចំតាក់តែងបទប្បញ្ញត្តិឡើងវិញ ឬបំពេញបន្ថែម ស្របតាមគោលការណ៍ទូទៅ គោលការណ៍គ្រឹះ តាមវិស័យជាក់លាក់<br>- ធានាបានការគោរពគោលការណ៍ឋានានុក្រមនៃលិខិតបទដ្ឋានគតិយុត្ត<br>- លុបបំបាត់ភាពដាច់ដោយដុំៗ និងភាពមិនច្បាស់លាស់នៃបទដ្ឋានគតិយុត្តក្នុងវិស័យតែមួយ និងធានាឯកសណ្ឋានគតិយុត្ត<br>- បញ្ជាក់អំពីភាពច្បាស់លាស់នៃលិខិតបទប្បញ្ញត្តិដែលស្រពេចស្រពិល និងធានាសុខដុមនីយកម្មនៃបទដ្ឋានគតិយុត្ត ដែលកំពុងស្ថិតនៅជាធរមាន<br>- កាត់បន្ថយអតិផរណានៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ដោយគិតគូរទៅលើភាពធន់នៃច្បាប់<br>- បង្ហាញពីវិធាននិងនីតិវិធីនៃការអនុវត្ត និងការត្រួតពិនិត្យ | - ការចំណាយធនធាន ទាំងធនធានមនុស្ស ធនធានសម្ភារៈ និងធនធានហិរញ្ញវត្ថុ ក្នុងកម្រិតខ្ពស់ ដើម្បីប្រមូល ពិនិត្យ ផ្ទៀងផ្ទាត់<br>- ភាពស្មុគស្មាញ និងប្រើប្រាស់ពេលវេលាយូរសម្រាប់ការសិក្សា រៀបចំ និងបំពេញនីតិវិធី<br>- ការកើតឡើងនៃវិវាទគតិយុត្តដែលទាមទារឱ្យមានការនិរាករណ៍ ឬធ្វើវិសោធនកម្ម<br>- តម្រូវការវិធីសាស្ត្រ និងធនធានសម្រាប់រៀបចំតម្រូវការនៃការធ្វើក្រម ទាំងទិដ្ឋភាពនយោបាយ ទិដ្ឋភាពគតិយុត្តនិងទិដ្ឋភាពបច្ចេកទេស<br>- ត្រូវការធនធានមនុស្ស ជាអ្នកច្បាប់មានជំនាញខ្ពស់ និងការសម្របសម្រួលពីក្រសួង ស្ថាប័នពាក់ព័ន្ធ | ប្រទេសបារាំងមានក្រមចំនួន ៧០ តាមវិស័យ និងមានគណៈកម្មការជាន់ខ្ពស់ក្រម នីយកម្ម ដែលមាននាយករដ្ឋមន្ត្រីជាប្រធាន។<br>ជាក់ស្តែង កម្ពុជាមានក្រមចំនួន ៥ ដូចជា ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមបរិស្ថាន។ បន្ថែមពីនេះ កម្ពុជា ក៏ធ្លាប់មានក្រមពាណិជ្ជកម្ម ឆ្នាំ១៩៦១ផងដែរ។ ក្នុងន័យនេះ ការរៀបចំជា "ក្រម" គួរត្រូវបានលើកយកមកសិក្សាក្នុងការធានាបាននូវសន្តិសុខគតិយុត្ត ក្នុងវិស័យសំខាន់ៗ ចាំបាច់ |

| ប្រភេទ | គុណប្រយោជន៍ | គុណវិបត្តិ | ជម្រើស |
|---|---|---|---|
| | - ផ្តល់ភាពងាយស្រួលក្នុងការពិនិត្យ ប្រឹក្សា ស្វែងរក ស្វែងយល់ អំពីវិធានគតិយុត្តក្នុងវិស័យជាក់លាក់។ | ដើម្បីប្រមូល និងកំណត់ពីធរមាននៃច្បាប់និងលិខិតបទដ្ឋានគតិយុត្ត<br>- ត្រូវការអ្នកច្បាប់មានជំនាញខ្ពស់ ក្នុងវិស័យ ឬប្រធានបទជាក់លាក់ ដើម្បីវិភាគ វាយតម្លៃ រៀបចំមាតិកា ខ្លឹមសារ ដែលអាចឈានដល់ការធ្វើនិរាករផ្នែក ឬអត្ថបទច្បាប់ទាំងស្រុង និងអាចរៀបចំតាក់តែងថ្មីបំពេញបន្ថែម<br>- ទាមទារឱ្យមានការឯកភាព និងដឹកនាំការរៀបចំក្នុងកម្រិតនយោបាយ | ដែលប្រទាក់ក្រឡាគ្នា ដើម្បីបង្កើតបរិស្ថានរួមមួយជួយសម្រួលការងារប្រចាំថ្ងៃ និងដោះស្រាយបញ្ហាវិវាទគតិយុត្ត ក៏ដូចជាការជាន់សមត្ថកិច្ចនៃស្ថាប័នបកស្រាយ និងស្ថាប័នអនុវត្តច្បាប់ជាដើម។ |

## ២.២ វិធីសាស្ត្រនៃការរៀបចំក្រមនៅកម្ពុជា

សញ្ញាណនៃពាក្យថា "ក្រម" ត្រូវបានយកមកប្រើប្រាស់តាំងពីសម័យអង្គរ ដូចជា ក្រមព្រះធម្មសាស្ត្រ ក្រមអថ៌សាស្ត្រ ដែលព្រះមហាក្សត្របានលើកតម្កើងជាច្បាប់កំពូលនិងគោរពប្រតិបត្តិ សម្រាប់ដឹកនាំប្រទេសផង និងគ្រប់គ្រងប្រជានុរាស្ត្រផង។

តាមរយៈកិច្ចខិតខំប្រឹងប្រែងពង្រឹងនីតិរដ្ឋ និងការធ្វើទំនើបកម្មច្បាប់នៅកម្ពុជា រាជរដ្ឋាភិបាល ចាប់តាំងពីចុងនីតិកាលទី២ នៃរដ្ឋសភា រហូតដល់នីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលបានធ្វើការកែទម្រង់ទាំងក្នុងក្របខ័ណ្ឌច្បាប់ ទាំងយន្តការស្ថាប័ន និងយន្តការអនុវត្ត ដោយបានសម្រេចនូវសមិទ្ធផលជាប្រវត្តិសាស្ត្រតាមរយៈការរៀបចំ និងអនុម័តនូវក្រមធំៗទាំង៥ រួមមានក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមបរិស្ថាននិងធនធានធម្មជាតិ។ វិធីសាស្ត្រក្នុងការតាក់តែងក្រមនីមួយៗ ត្រូវបានរៀបចំឡើងតាមរយៈវិធីសាស្ត្រដោយឡែកពីគ្នា អាស្រ័យលើចរិតលក្ខណៈនៃវិស័យនីមួយៗ ជំនួយពីដៃគូអភិវឌ្ឍន៍និងបណ្តាប្រទេសជាមិត្ត។

ចំពោះយន្តការស្ថាប័ននៃការរៀបចំក្រមទាំង៥ខាងលើ គឺដូចទៅនឹងការតាក់តែងច្បាប់ ដោយក្រសួង ស្ថាប័នសាមី ជាអ្នករៀបចំសេចក្តីព្រាង ឆ្លងកាត់ការពិគ្រោះយោបល់កម្រិតចង្អៀត/ទូលាយ ការពិនិត្យនិងផ្តល់យោបល់ពីទីស្តីការគណៈរដ្ឋមន្ត្រីទាំងទិដ្ឋភាពទូទៅនិងទិដ្ឋភាពបច្ចេកទេស (ទម្រង់ ខ្លឹមសារ) និងដាក់ឆ្លងគណៈកម្មការជំនាញរបស់សភាពិនិត្យលើខ្លឹមសារ មុននឹងអនុម័តនិងប្រកាសដាក់ឱ្យអនុវត្តដោយព្រះមហាក្សត្រ។ ចំណុចកត់សម្គាល់ គឺក្នុងកម្រិតបច្ចេកទេស ក្រមត្រូវរៀបចំឱ្យមានមាតិកា ប៉ុន្តែសភាមិនអនុម័តលើមាតិកានោះទេ។ មាតិកានៃក្រម អាចភ្ជាប់បាននៅក្នុងក្រមនៅពេលបោះពុម្ពផ្សាយជាសៀវភៅសម្រាប់ផ្សព្វផ្សាយប៉ុណ្ណោះ។ រីឯវិធីសាស្ត្រនៃការកំណត់មាតិកាពិស្តារ ចាប់ផ្តើមពី គន្ថី មាតិកា ជំពូក ផ្នែក មាត្រា ហើយលេខមាត្រានៅក្នុងក្រម ត្រូវបានរៀបចំឡើងតាមលំដាប់លំដោយពីមាត្រា១ នៅក្នុងជំពូកបទប្បញ្ញត្តិទូទៅរហូតដល់មាត្រាចុងក្រោយនៅក្នុងជំពូកក្រោយបង្អស់នៃអវសានប្បញ្ញត្តិ។

ក្នុងន័យនេះ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមបរិស្ថាននិងធនធានធម្មជាតិ នឹងលើកឡើងជាករណីសិក្សា ដើម្បីធ្វើការវិភាគឱ្យបានស៊ីជម្រៅលើទិដ្ឋភាពនៃការរៀបចំក្រមនៅកម្ពុជា ដូចមានក្នុងឧបសម្ព័ន្ធទី១ ភ្ជាប់មកជាមួយទស្សនាទាននេះ។

# ៣. អំពីពាណិជ្ជកម្ម

## ៣.១ ប្រភេទនៃទំនាក់ទំនងពាណិជ្ជកម្ម

យោងតាមសៀវភៅ Business Model Generation: A Handbook for Visionaries, Game Changers, and Challengers (Osterwalder and Pigneur ២០១០) បានកំណត់នូវប្រភេទទំនាក់ទំនងក្នុងអាជីវកម្ម និងម៉ូឌែល Hybrid សម្រាប់ជួយដល់ការរៀបចំយុទ្ធសាស្ត្រអាជីវកម្ម

ប្រកបដោយប្រសិទ្ធភាព និងបង្កើតនូវគុណតម្លៃបន្ថែម។ ទំនាក់ទំនងក្នុងអាជីវកម្ម រួមមាន បីប្រភេទ ដូចខាងក្រោម៖

- ❖ អាជីវកម្ម និងអាជីវកម្ម (Business to Business)៖ សំដៅដល់អាជីវកម្មមួយ បង្កើននូវតម្លៃសម្រាប់អាជីវកម្មមួយ ឬច្រើនផ្សេងទៀត ដូចជាក្រុមហ៊ុន រោងចក្រ និងស្ថាប័នរកប្រាក់ចំណេញ តាមរយៈការចុះកិច្ចសន្យាពាណិជ្ជកម្មជាដើម។ ឧទាហរណ៍៖ ក្រុមហ៊ុន Software បានផ្តល់ប្រព័ន្ធគណនេយ្យ ជូនដល់ក្រុមហ៊ុនផ្សេងទៀតដែលមានតម្រូវការ។
- ❖ អាជីវកម្ម និងអ្នកប្រើប្រាស់ចុងក្រោយ (Business to Consumer)៖ សំដៅដល់ការធ្វើអាជីវកម្មជាមួយនឹងអ្នកប្រើប្រាស់ចុងក្រោយ ជារូបវន្តបុគ្គលដោយផ្ទាល់។ ឧទាហរណ៍៖ ហាងលក់សម្លៀកបំពាក់ អាហារ ឧបករណ៍អេឡិចត្រូនិកជាដើម។
- ❖ អាជីវកម្ម និងរដ្ឋាភិបាល (Business to Government)៖ សំដៅដល់ការធ្វើអាជីវកម្ម ជូនក្រសួង ស្ថាប័ន តាមរយៈការដេញថ្លៃ និងស្តង់ដាររបស់រដ្ឋាភិបាលដែលបានកំណត់នៅក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។ ឧទាហរណ៍៖ ក្រុមហ៊ុនសាងសង់ ដែលដេញថ្លៃបានសម្រាប់ការសាងសង់ស្ពាន សាលារៀនរដ្ឋជាដើម។

## ៣.២ ក្របខ័ណ្ឌគតិយុត្តក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិ

ក្នុងក្របខ័ណ្ឌនីតិពាណិជ្ជកម្មអន្តរជាតិ លិខិតូបករណ៍អន្តរជាតិដែលគ្រប់គ្រងទំនាក់ទំនងពាណិជ្ជកម្ម អាចត្រូវបានពិនិត្យមើលលើទិដ្ឋភាពចម្បងចំនួន ២ គឺទី១. ទិដ្ឋភាពនៃនីតិអន្តរជាតិឯកជន (International/Transnational Private Law) និងទី២. ទិដ្ឋភាពនៃនីតិអន្តរជាតិសាធារណៈ (Public International Law)។ នីតិអន្តរជាតិឯកជន គឺជាយន្តការគ្រប់គ្រងទំនាក់ទំនងអន្តរជាតិតាមរយៈ អន្តរាគមន៍ដោយប្រយោល (Indirect Intervention) ទៅលើវិវាទ និងសណ្តាប់ធ្នាប់ឯកជនដែលក្នុងនោះរដ្ឋកំណត់នូវបទដ្ឋានគតិយុត្ត និងនីតិវិធីសម្រាប់ភាគីឯកជនប្រើប្រាស់ក្នុងករណីដែលមានវិវាទ។[12] នៅក្នុងបរិបទនៃធុរកិច្ចអន្តរជាតិ នីតិអន្តរជាតិឯកជនមានតួនាទីយ៉ាងសំខាន់ក្នុងការ៖ (១) សម្របសម្រួលប្រតិបត្តិការពាណិជ្ជកម្ម[13] (២) កំណត់វិធានគ្រប់គ្រងប្រតិបត្តិការ និងយន្តការដោះស្រាយវិវាទ និង (៣) ការរៀបចំបទដ្ឋានគតិយុត្តស្តង់ដាសម្រាប់បញ្ចូលជាខសន្យានៅក្នុងកិច្ចសន្យាឯកជនអន្តរជាតិ។[14] ដោយឡែក ចំពោះទំនាក់ទំនងគតិយុត្តក្នុងកម្រិត ទ្វេភាគី ពហុភាគីឬកម្រិតតំបន់ ឬស្ថាប័នអន្តរជាតិ ដែលតម្រូវឱ្យមានការព្រមព្រៀងពីរដ្ឋសមាជិកឬរដ្ឋភាគី នឹងបង្កើតឱ្យមានចំណងកាតព្វកិច្ចអន្តរជាតិ (International Obligations) ដែលជាផ្នែកមួយនៃដែនសមត្ថកិច្ចនៃនីតិអន្តរជាតិសាធារណៈ ពីព្រោះចំណងទាំងនោះបានបង្កើតកាតព្វកិច្ចលើរដ្ឋភាគី។[15] ការពិភាក្សា

---

[12] Robert Wai, 'Transnational Private Law and Private Ordering in a Contested Global Society Global Society' (2005) 46(2) Harvard International Law Journal page 471, 475.
[13] Transaction facilitation, ex: L/C, Factoring, SWIFT Wire Transfer …
[14] Robert Wai, 'The Interlegality of Transnational Private Law' (2008) 71(107) Law and Contemporary Problems 107, 108.
[15] Joost Pauwelyn, 'The Role of Public International Law in the WTO: How Far Can We Go?' (2001) 95(3) The American Journal of International Law 535, 536-538.

លម្អិតជាងនេះបង្ហាញថាវិធានច្បាប់ដែលគ្រប់គ្រងទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសគឺជាផ្នែកមួយនៃនីតិសេដ្ឋកិច្ចអន្តរជាតិ[16] ហើយនីតិសេដ្ឋកិច្ចអន្តរជាតិជាផ្នែកមួយនៃនីតិអន្តរជាតិសាធារណៈ។[17]

ដូចនេះ នីតិពាណិជ្ជកម្មអន្តរជាតិអាចពិភាក្សាបានជា ២ កម្រិត៖ កម្រិតរដ្ឋ (នីតិអន្តរជាតិសាធារណៈ) ដែលរដ្ឋបង្កើតវិធាននិងសន្ធិសញ្ញាពាណិជ្ជកម្មដោយចងកាតព្វកិច្ចដល់រដ្ឋភាគីឬរដ្ឋសមាជិក និងកម្រិតឯកជន (នីតិអន្តរជាតិឯកជន) ដែលពាណិជ្ជករអនុវត្តប្រតិបត្តិការតាមកិច្ចសន្យា។ ជារួម នីតិអន្តរជាតិឯកជនធ្វើឱ្យប្រតិបត្តិការជួញដូរអាចកើតឡើងបាន ចំណែកនីតិអន្តរជាតិសាធារណៈបង្កើតជាទីផ្សារសម្រាប់ឱ្យពាណិជ្ជករមានប្រតិបត្តិការបាន និងការបង្កើតនូវលិខិតបទដ្ឋានគតុយុត្តក្នុងទីផ្សារ (Market Regulation) សម្រាប់ពាណិជ្ជករត្រូវអនុលោមតាម។

ការបែងចែកក្របខ័ណ្ឌនីតិពាណិជ្ជកម្មអន្តរជាតិជា ២ បែបនេះ បានបង្កើតភាពងាយស្រួលក្នុងការរៀបចំក្រមពាណិជ្ជកម្ម ដោយហេតុថាការបែងចែកដោយបញ្ជាក់ពីតួអង្គ (Subjects/Actors) ផ្ដល់ជាមូលដ្ឋានក្នុងការសម្រេចចិត្តសម្រាប់វិសាលភាពនៃការគ្រប់គ្រង (តើក្រមពាណិជ្ជកម្មមានវិសាលភាពគ្រប់គ្រងដល់តួអង្គណាខ្លះ?)។ ដូចនេះ ការជ្រើសរើសសំណុំនៃវិធានអន្តរជាតិដែលគួរដាក់បញ្ចូល និងសំណុំដែលមិនគួរដាក់បញ្ចូល ពុំតម្រូវឱ្យមានការពិនិត្យគ្រប់វិធានអន្តរជាតិទាំងអស់ក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិឡើយ។

### ៣.២.១ ក្របខ័ណ្ឌនីតិពាណិជ្ជកម្មអន្តរជាតិសាធារណៈ

ជាទូទៅ នីតិពាណិជ្ជកម្មអន្តរជាតិសាធារណៈ គឺជាក្របខ័ណ្ឌដែលកើតពីសំណុំវិធានអន្តររដ្ឋ បើទោះបីជាវិធានទាំងនោះជះឥទ្ធិពលផ្ទាល់ទៅដល់ភាគីឯកជននៅក្នុងប្រតិបត្តិការពាណិជ្ជកម្មអន្តរជាតិក៏ដោយ ក៏កាតព្វកិច្ចអន្តរជាតិ និងសិទ្ធិនានាមានអានុភាពទៅលើតែរដ្ឋភាគីប៉ុណ្ណោះ (ឧ. យន្តការដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) គឺមានអានុភាពត្រឹមរដ្ឋភាគីប៉ុណ្ណោះ មិនអាចពន្លាតទៅដល់ភាគីឯកជនទេ)។[18] ដូចនេះ ភាគីពាក់ព័ន្ធនៅក្នុងក្របខ័ណ្ឌនីតិពាណិជ្ជកម្មអន្តរជាតិសាធារណៈមាន រដ្ឋាភិបាល និងអង្គការអន្តរជាតិជាដើម ។[19] អន្តរកម្មរវាងភាគីទាំងនេះមានក្រោមរូបភាព (១) រដ្ឋ (ជាតួអង្គចំបង) ជានីតិករនៃច្បាប់ជាតិរបស់ខ្លួននិងជាភាគីដែលត្រូវអនុវត្តកាតព្វកិច្ចអន្តរជាតិ[20] (២) អង្គការអន្តរជាតិ (ជាតួអង្គបន្ទាប់បន្សំ) ជាស្ថាប័នកើតពីឆន្ទៈរបស់ភាគីចម្បងដើម្បីឆ្ពោះទៅរកគោលដៅរួមណាមួយតាមរយៈការបង្កើតកាតព្វកិច្ចអន្តរជាតិដល់រដ្ឋភាគី។[21]

---

[16] Peter Van and Marie Denise Prévost, *Essentials of WTO Law* (2nd edn., Cambridge University Press 2021) 4-5.
[17] Donald McRae, 'International Economic Law and Public International Law: The Past and the Future' (2014) 17(3) Journal of International Economic Law 627, 629.
[18] Pierfrancesco Rossi, 'The Subjects, Actors and Sources of International Economic Law' in Fulvio M Palombino (ed), *Introduction to International Economic Law* (Routledge 2025) 24-25.
[19] Ibid 7-29.
[20] Ibid 9-10.
[21] Ibid 16.

*ចំណាំ៖* ភាគីឯកជនក៏អាចជាតួអង្គមួយបានដែរ លុះត្រាតែមានការផ្តល់សិទ្ធិ និងកាតព្វកិច្ចដោយលិខិតូបករណ៍អន្តរជាតិណាមួយ។[22]

បន្ថែមពីនេះ រដ្ឋអាចធ្វើសមាហរណកម្មបានក្នុងករណីដែលមានឧបសគ្គនៃលំហូរសេដ្ឋកិច្ចមានកម្រិតអប្បបរិមា ដែលឧបសគ្គទាំងនោះមានទម្រង់ជា របាំងពាណិជ្ជកម្ម (ការនាំចេញ-នាំចូល) ការគ្រប់គ្រងលំហូរសាច់ប្រាក់ របាំងនៃការវិនិយោគ ការផ្ទេរបច្ចេកវិទ្យា និងប្រតិបត្តិការអចលនវត្ថុ ហើយប្រសិនបើឧបសគ្គទាំងនោះត្រូវបានដកចេញ រដ្ឋនឹងអាចធ្វើសមាហរណកម្មបាន។[23] ឧបសគ្គទាំងនេះអាចដកចេញបានដោយឯកតោភាគី ទ្វេរភាគី ឬដោយពហុភាគី តាមរយៈការបង្កើតស្ថាប័នអន្តរជាតិដើម្បីពិនិត្យមើលការខុសត្រូវកិច្ចព្រមព្រៀងទាំងនោះ។[24]

## ក. កម្រិតស្ថាប័នអន្តររដ្ឋាភិបាល៖ អង្គការពាណិជ្ជកម្មពិភពលោក

កម្ពុជា បានចំណាយពេលជិត ១០ឆ្នាំ សម្រាប់ការចរចារអំពីលក្ខខណ្ឌនៃការចូលរួមក្នុងអង្គការពាណិជ្ជកម្មពិភពលោក (WTO)។[25] ការចូលជាសមាជិក WTO របស់កម្ពុជា បានទទួលសច្ចាប័នពីរដ្ឋសភា និងបានទទួលការអនុម័តយល់ព្រមពីព្រឹទ្ធសភា នៅក្នុងខែកញ្ញា ឆ្នាំ២០០៤ និងបានក្លាយជាសមាជិកពេញសិទ្ធិ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤។[26] សំណុំលិខិតបទដ្ឋានគតិយុត្តរបស់ WTO មានលក្ខណៈស្មុគស្មាញ រួមជាមួយនឹងកិច្ចព្រមព្រៀងនានាដែលសមាជិកទាំងអស់ត្រូវតែគោរពប្រតិបត្តិដោយពេញលេញ ដែលត្រូវបានហៅថា កាតព្វកិច្ចពហុភាគី។

ការចូលជាសមាជិក WTO គឺជាកិច្ចព្រមព្រៀងដែលមានចំណងគតិយុត្តិរវាងសមាជិកទាំងអស់ ជាមួយសមាជិកថ្មីៗ ដែលកិច្ចព្រមព្រៀងនេះបញ្ជាក់អំពីលក្ខខណ្ឌលម្អិតនៃពាណិជ្ជកម្មរវាងរដ្ឋជាសមាជិក និងបញ្ជាក់អំពីការយល់ដឹងលើទិដ្ឋភាពទីផ្សារ ច្បាប់ ដំណើរការនៃការដោះស្រាយវិវាទរវាងរដ្ឋនឹងរដ្ឋនៅ WTO និងលក្ខខណ្ឌវិនិយោគនានា។ ក្នុងស្មារតីនោះ មុនពេលចូលជារដ្ឋសមាជិកកម្ពុជាបានធ្វើការសន្យាជាមួយ WTO នៅចំណុចដូចខាងក្រោម (បញ្ជីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមានក្នុងតារាងឧបសម្ព័ន្ធទី៣)៖[27]

- **ការគ្រប់គ្រងតម្លៃ៖** នៅពេលកម្ពុជាចូលជារដ្ឋសមាជិក របបនៃការគ្រប់គ្រងតម្លៃត្រូវតែស្របតាមវិធានរបស់ WTO ដោយមានការគិតគូរអំពីផលប្រយោជន៍នៃការនាំចេញរបស់រដ្ឋភាគី WTO ដទៃ។ កម្ពុជាបានដាក់ចេញនូវតារាងនៃទំនិញ និងសេវាកម្មដែលស្ថិតក្នុងការគ្រប់គ្រងរបស់រដ្ឋរួចរាល់។

[22] See: Ibid 22-25.
[23] Aseem Prakash and Jeffrey Hart, 'Indicators of Economic Integration' (2000) 6(1) Global Governance: A Review of Multilateralism and International Organizations 95, 95-96.
[24] Ibid.
[25] Fuzhi Cheng, 'Cambodia's WTO Accession' (Per Pinstrup-Andersen ed, Cornell University 2007) 1.
[26] Protocol Reference No. WLI/100 on the Accession of the Kingdom of Cambodia to the Marrakesh Agreement Establishing the World Trade Organization (dated 13 October 2004).
[27] See: https://www.wto.org/english/thewto_e/acc_e/factsheet_cambodge_e.htm

- **សិទ្ធិក្នុងការនាំចេញ-នាំចូល៖** ឆ្លើយតបទៅនឹងមតិថា ការរឹតត្បិតនានារបស់កម្ពុជាទៅលើផលិតផលឱសថ និងថ្នាំសត្វអាចជាការរើសអើងដែលផ្តល់អាទិភាពដល់ផលិតផលក្នុងស្រុកស្រដៀងគ្នានោះ កម្ពុជាបានថ្លែងថា យ៉ាងយូរបំផុតត្រឹមថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៥ ខ្លួននឹងធ្វើវិសោធនកម្មច្បាប់ និងជានាច្បាប់ឱ្យស្របតាមកាតព្វកិច្ចរបស់ WTO ទាំងស្រុង។
- **កម្រៃ និងសេវាសម្រាប់ការផ្តល់សេវា៖** រាល់កម្រៃ និងសេវាដែលប្រមូលបានសម្រាប់ការផ្តល់សេវាពាក់ព័ន្ធនឹងការនាំចូល និងនាំចេញ នឹងត្រូវអនុលោមតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង WTO ហើយចាប់ពីថ្ងៃចូលជាសមាជិក កម្ពុជានឹងមិនអនុវត្ត ណែនាំ ឬដាក់ឱ្យប្រើប្រាស់ឡើងវិញនូវកម្រៃ និងសេវាសម្រាប់ការផ្តល់សេវា ដែលធ្លាប់ត្រូវបានអនុវត្តលើការនាំចូលតាមតម្លៃទំនិញ ( Ad Valorem) (ជាភាគរយនៃតម្លៃទំនិញ ) នោះឡើយ។
- **ការអនុវត្តពន្ធផ្ទៃក្នុង៖** ចាប់ពីថ្ងៃចូលជាសមាជិក កម្ពុជានឹងអនុវត្តពន្ធក្នុងស្រុករបស់ខ្លួនដោយអនុលោមតាមមាត្រា ៣ នៃ GATT យ៉ាងតឹងរ៉ឹង និងគ្មានការរើសអើងចំពោះការនាំចូលទោះបីជាមកពីប្រទេសដើមកំណើតណាក៏ដោយ។ មាត្រា ៣ នៃ GATT ពាក់ព័ន្ធនឹង "ការផ្តល់ប្រព្រឹត្តិកម្មជាតិ "national treatment" ក្នុងការបង់ពន្ធ។

ជាគោលការណ៍ រដ្ឋដែលចូលជាសមាជិក WTO តម្រូវឱ្យមានការតម្រង់ទិសផ្នែកច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា ឱ្យអនុលោមតាមឧបសម្ព័ន្ធ ១ ដល់ ៣ នៃកិច្ចព្រមព្រៀងបង្កើតអង្គការពាណិជ្ជកម្មពិភពលោក។ ឧបសម្ព័ន្ធទាំងនោះរួមមានកិច្ចព្រមព្រៀងមួយចំនួនដូចជា៖

**ANNEX 1**

1. General Agreement on Tariffs & Trade 1994
2. Agreement on Agriculture
3. Agreement on Application of Sanitary & Phytosanitary Measures
4. Agreement on Textiles & Clothing
5. Agreement on Technical Barriers to Trade
6. Agreement on Trade-Related Investment Measures
7. Agreement on Application of Art. VI of GATT 1994
8. Agreement on Application of Art. VII of GATT 1994
9. Agreement on Preshipment Inspection
10. Agreement on Import Licensing Procedures
11. Agreement on Subsidies & Countervailing Measures
12. Agreement on Safeguards
13. General Agreement on Trade in Services & Annexes
14. Agreement on Trade-Related Aspects of Intellectual Property Rights

**ANNEX 2**

Understanding on Rules & Procedures Governing the Settlement of Disputes

**ANNEX 3**

Trade Policy Review Mechanism

យោងតាមប្រសាសន៍សំខាន់ៗរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសអញ្ជើញជាអធិបតី អបអរសាទរខួប ២០ឆ្នាំ នៃកម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៤ " ច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យពាណិជ្ជកម្ម គប្បីប្រមូលផ្តុំឱ្យមានលក្ខណៈពេញលេញ ប្រទាក់ក្រឡា សង្គតិភាព និងឥតខ្វះចន្លោះ ជាមួយនឹងការកំណត់នូវមុខងារភារកិច្ចរបស់ស្ថាប័ន ក្នុងដវភាពនៃប្រព័ន្ធតួអង្គតែមួយ" ដើម្បីត្រៀមចាកចេញដោយរលូន ពីចំណាត់ថ្នាក់ប្រទេសមានការអភិវឌ្ឍតិចតួច ដែលមានគោលដៅកាត់បន្ថយ ឬ លុបបំបាត់ ផលប៉ះពាល់អវិជ្ជមាន ដែលកើតចេញពីការបាត់បង់ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងវិធានការ ជំនួយអន្តរជាតិនានា ក៏ដូចជា ការធានាបាននូវចីរភាពនៃការអភិវឌ្ឍ ក្រោយការចាកចេញនៅឆ្នាំ២០២៩។

### ខ. កម្រិតទ្វេភាគី និងតំបន់

ក្នុងការអនុវត្តអភិក្រម «**ពង្រឹងទីផ្សារចាស់-ពង្រីកទីផ្សារថ្មី**» រាជរដ្ឋាភិបាលបានបន្តលើកកម្ពស់ការអនុវត្ត និងការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ក្នុងកម្រិតទ្វេភាគី តំបន់ និងពហុភាគីដែលមានស្រាប់។ រាជរដ្ឋាភិបាលក៏បានកំណត់ចេញនូវគោលការណ៍ស្វែងរកច្រកទីផ្សារនាំចេញ ឬ ដៃគូពាណិជ្ជកម្មសក្តានុពលថ្មីៗ ដោយជំរុញការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីបន្ថែមទៀត ដើម្បីពង្រីកទីផ្សារឱ្យមានលក្ខណៈរីកតែទូលំទូលាយ។

ក្រៅពីក្របខ័ណ្ឌ WTO កម្ពុជាជារដ្ឋភាគីជាមួយនឹងលិខិតូបករណ៍អន្តរជាតិមួយចំនួននៅក្នុងវិស័យនីតិពាណិជ្ជកម្មសាធារណៈ និងវិនិយោគអន្តរជាតិសាធារណៈរួមមាន អនុសញ្ញាស្តីពីការដោះស្រាយវិវាទវិនិយោគរវាងរដ្ឋ និងបុគ្គលនៃរដ្ឋដទៃ (Convention on the Settlement of Investment Disputes between States and Nationals of Other States), សន្ធិសញ្ញាវិនិយោគទ្វេភាគីចំនួន ២៧ [28], កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីចំនួន៣, [29] កិច្ចព្រមព្រៀងពាណិជ្ជកម្មក្នុងក្របខ័ណ្ឌ ASEAN មួយចំនួន, និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP)។

### ៣.២.២ ក្របខ័ណ្ឌច្បាប់ពាណិជ្ជកម្មអន្តរជាតិឯកជន

ឧត្តមានុវត្តន៍របស់ពាណិជ្ជករក្នុងពាណិជ្ជកម្មអន្តរជាតិឆ្លុះបញ្ចាំងពីបទពិសោធ និងការអនុវត្តដែលនឹងបន្តប្រើប្រាស់នាពេលអនាគត។ ដូចនេះ តួអង្គពាក់ព័ន្ធនៅក្នុងក្របខ័ណ្ឌច្បាប់ពាណិជ្ជកម្មអន្តរជាតិឯកជនគឺ ភាគីវិស័យឯកជនតែប៉ុណ្ណោះ ដែលរួមបញ្ចូលនូវស្ថាប័នអន្តរជាតិនានាដូចជា International Institute for the Unification of Private Law (UNIDROIT), United Nations Commission on International Trade Law (UNCITRAL), និង International Chamber of Commerce (ICC) ដែលស្ថាប័នទាំងនេះបង្កើតនូវ វិធានទន់ (Soft Law) គំរូកិច្ចសន្យា និងគំរូច្បាប់ (Model Law) ដែលគ្រប់គ្រងប្រតិបត្តិការពាណិជ្ជកម្ម។ ដូចនេះ ការរៀបចំក្រមតម្រូវឱ្យមានការ

[28] See: https://investmentpolicy.unctad.org/international-investment-agreements/countries/33/cambodia
[29] យោងតាមគេហទំព័រក្រសួងពាណិជ្ជកម្ម

ពិចារណាលើលិខិតូបករណ៍ទាំងអស់ខាងលើ ដើម្បីសមាហរណកម្មច្បាប់ពាណិជ្ជកម្ម។ ការពិភាក្សាបន្ថែមទៅលើស្ថាប័ន និងលិខិតូបករណ៍នានាមានដូចខាងក្រោមៈ

### ក. UNIDROIT

UNIDROIT គឺជាអង្គការអន្តររដ្ឋាភិបាលឯករាជ្យដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩២៦ និងមានមូលដ្ឋាននៅទីក្រុងរ៉ូម ប្រទេសអ៊ីតាលី។ គោលបំណងចម្បង គឺសិក្សាអំពីតម្រូវការ និងវិធីសាស្ត្រសម្រាប់ការធ្វើទំនើបកម្មគតិយុត្ត ការធ្វើសុខដុមនីយកម្ម និងការសម្របសម្រួល រវាងរដ្ឋនិងបណ្តារដ្ឋផ្សេងទៀតក្នុងច្បាប់ឯកជន (Private law)។ ជាពិសេសច្បាប់ពាណិជ្ជកម្មអន្តរជាតិ ដែលទាក់ទងនឹងកិច្ចសន្យា ប្រតិបត្តិការពាណិជ្ជកម្ម ហិរញ្ញវត្ថុ ប្រតិបត្តិការដែលមានកិច្ចធានា នីតិវិធីរដ្ឋប្បវេណី និងបញ្ហាអាជីវកម្មអន្តរជាតិដទៃទៀត ដោយការបង្កើតលិខិតូបករណ៍ វិធានច្បាប់ និងគោលការណ៍ច្បាប់ មគ្គុទ្ទេសក៍សិល្បសាស្ត្រ (legal Guides) ជាស្តង់ដាគតិយុត្តរួមដែលមានសង្គតិភាព សម្រាប់តុលាការ មជ្ឈត្តការពាណិជ្ជកម្ម(Arbitral Tribunal) ឬភាគីនៃកិច្ចសន្យាយកទៅដោះស្រាយលើបញ្ហាទាក់ទងនឹងធុរកិច្ចអន្តរជាតិ។ ក្នុងនោះ គោលការណ៍សំខាន់ របស់ UNIDROIT គឺគោលការណ៍កិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិ (UNIDROIT Principles of International Commercial Contracts - UPICC) ដែលផ្តល់នូវវិធានទូទៅសម្រាប់កិច្ចសន្យាពាណិជ្ជកម្ម ដោយអាចនឹងត្រូវប្រើប្រាស់បានដោយភាគីនៃកិច្ចសន្យា តុលាការ និងមជ្ឈត្តការពាណិជ្ជកម្ម ដើម្បីជាមគ្គុទ្ទេសក៍ក្នុងការបកស្រាយឬបំពេញបន្ថែមលើវិធាននៃកិច្ចសន្យា។ គោលការណ៍នេះដំណើរការក្នុងនាមជា វិធានទន់ (Soft law) មិនមានកាតព្វកិច្ចផ្លូវច្បាប់(Non-binding) ដែលមានន័យថា UPICC អាចត្រូវបានជ្រើសរើសដោយភាគីជម្លោះនៅក្នុងកិច្ចសន្យា និងប្រើប្រាស់ដោយតុលាការ ឬមជ្ឈត្តការពាណិជ្ជកម្ម ដើម្បីបកស្រាយ ឬបំពេញបន្ថែមលើច្បាប់ក្នុងស្រុក និងឯនខកសណ្ឋាននៃលិខិតូបករណ៍អន្តរជាតិ(International Uniform law instrument)។ ក្នុងនោះ អនុសញ្ញាសំខាន់ៗ និងពិធីសារចំនួន៤ទាក់ទងនឹងវិស័យពាណិជ្ជកម្មរួមមានៈ

- UNIDROIT Convention on International Financial Leasing 1988
- UNIDROIT Convention on International Factoring 1988
- Convention on Agency in the International Sale of Goods 1983
- Cape Town Convention on International Interests in Mobile Equipment 2001
- Aircraft Protocol, 2001
- Luxembourg Rail Protocol, 2007
- Space Assets Protocol, 2012
- MAC Protocol, 2019

## ២. UNCITRAL

UNCITRAL ជាស្ថាប័នមួយនៅក្រោមអង្គការសហប្រជាជាតិដែលមានក្របខ័ណ្ឌក្នុងការធ្វើទំនើបកម្ម និងសុខដុមភាវូបនីយកម្មនៃច្បាប់ទាក់ទងនឹងវិស័យពាណិជ្ជកម្មអន្តរជាតិ។ UNCITRAL បំពេញកិច្ចការរៀបចំ នឹងជំរុញការប្រើប្រាស់នៃលិខិតូបករណ៍គតិយុត្ត និងលិខិតទន់នៅក្នុងប្រធានបទជាច្រើននៃនីតិពាណិជ្ជកម្ម( UNCITRAL Texts) ។ ក្នុងការផ្តល់ជំនួយបច្ចេកទេស (technical assistance) ទៅលើការកែទម្រង់ច្បាប់ UNCITRAL បានផ្តល់ជំនួយទៅបណ្តារដ្ឋ និងអ្នកប្រើប្រាស់ UNCITRAL Texts ក្នុងការ (១) បង្កើនការយល់ដឹង និងជម្រុញការអនុម័ត UNCITRAL Texts (២) ផ្តល់ជំនួយ និងប្រឹក្សាយោបល់ទៅរដ្ឋ លើការសិក្សាពីចន្លោះច្បាប់ (gap analysis) សម្រាប់ការកែទម្រង់ច្បាប់ពាណិជ្ជកម្ម និងនីតិកម្ម និង (៣) ការពង្រឹងស្ថាប័ន (capacity building) ដោយការបណ្តុះបណ្តាល UNCITRAL Texts ទៅអ្នកអនុវត្តច្បាប់ និងអង្គតុលាការ។

សម្រាប់នីតិពាណិជ្ជកម្មអន្តរជាតិឯកជនវិញ លិខិតូបករណ៍ដែលកម្ពុជា ក្នុងនាមជារដ្ឋសមាជិកគោរពអនុវត្តមានតែមួយប៉ុណ្ណោះគឺ អនុសញ្ញាទីក្រុង NEW YORK ស្តីពីការទទួលស្គាល់ និងអនុវត្តសេចក្តីសម្រេចមជ្ឈត្តការបរទេស ដែលនេះជាស្នាដៃរៀបចំរបស់ UNCITRAL មួយក្នុងចំណោមស្នាដៃនីតិកម្មមួយចំនួនដូចខាងក្រោម៖[30]

១. មជ្ឈត្តកម្ម៖ Model Law on International Commercial Arbitration 1985 (amended 2006) និង New York Convention on the Recognition and Enforcement of Foreign Arbitral Awards

២. សន្ធានកម្ម៖ Model Law on International Commercial Mediation and International Settlement Agreements Resulting from Mediation 2018 និង Singapore Convention on International Settlement Agreements Resulting from Mediation 2020.

៤. វិនិយោគ៖ Mauritius Convention on Transparency in Treaty-based Investor-State Arbitration 2024, Statute of the Advisory Centre on International Investment Dispute Resolution (adopted in principle in 2024 ), UNCITRAL Model Provisions on Mediation for International Investment Disputes 2023.

៥. ពាណិជ្ជកម្មអេឡិកត្រូនិក៖ Convention on the Use of Electronic Communications in International Contracts 2005, Model Law on Automated Contracting 2024, Model Law on the Use and Cross-border Recognition of Identity Management and Trust Services 2022, Model Law on Electronic Transferable Records 2017, Model Law on Electronic Signatures 2001, Model Law on Electronic Commerce 1996.

[30] See: https://uncitral.un.org/en/texts

៦. ការលក់ទិញទំនិញ៖ UN Convention on Contracts for the International Sale of Goods 1980.

៧. វិធានសម្រាប់សហគ្រាសមីក្រូ តូច និងមធ្យម៖ Guide on access to credit for micro, small and medium-sized enterprises 2023, Legislative Guide on Limited Liability Enterprises 2021, Legislative Guide on Insolvency Law for Micro- and Small Enterprises 2021, Legislative Guide on Key Principles of a Business Registry 2018

៨. ក្ស័យធន៖ Model Law on Enterprise Group Insolvency with Guide to Enactment 2019, Model Law on Recognition and Enforcement of Insolvency-Related Judgments with Guide to Enactment 2018, និង Model Law on Cross-Border Insolvency 1997 with Guide to Enactment and Interpretation 2013

៩. សិទ្ធិប្រាតិភោគ៖ Convention on the Assignment of Receivables in International Trade 2001, Model Law on Secured Transactions 2016,

១០. មធ្យោបាយទូទាត់ និងហិរញ្ញប្បទានពាណិជ្ជកម្ម៖ Convention on Independent Guarantees and Stand-by Letters of Credit 1995 និង Convention on International Bills of Exchange and International Promissory Notes 1988

១១. ការដឹកជញ្ជូន៖ Beijing Convention on the International Effects of Judicial Sales of Ships 2022, Convention on Contracts for the International Carriage of Goods Wholly or Partly by Sea 2008 ("Rotterdam Rules"), Convention on the Liability of Operators of Transport Terminals in International Trade 1991, Convention on the Carriage of Goods by Sea 1978 ("Hamburg Rules")

**ឌ. International Chamber of Commerce**

គោលបំណងជាមូលដ្ឋានរបស់សភាពាណិជ្ជកម្មអន្តរជាតិ(ICC) គឺដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចពិភពលោក បែបបើកចំហ(open world economy) ក្រោមជំហរថា ពាណិជ្ជកម្មអន្តរជាតិគឺជាកត្តាដែលនាំមកនូវទាំងវិបុលភាព និងសន្តិភាពសម្រាប់ប្រជាជាតិទាំងឡាយ។[៣១] គោលបំណងនេះបានបង្កើតឱ្យមានគោលដៅចម្បងចំនួនបី រួមមាន (១)ការលើកកម្ពស់ពាណិជ្ជកម្ម សេវាកម្ម និងការវិនិយោគអន្តរជាតិ ដោយការលុបបំបាត់ឧបសគ្គនៃពាណិជ្ជកម្មអន្តរជាតិ (២)ការលើកកម្ពស់ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារដែលផ្អែកលើគោលការណ៍នៃការប្រកួតប្រជែងដោយសេរី និងសមភាពក្នុងចំណោមសហគ្រាសអាជីវកម្ម និង(៣)ការបណ្តុះកំណើនសេដ្ឋកិច្ចនៃប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ជាពិសេសក្នុងគោលបំណងធ្វើសមាហរណកម្មប្រទេសទាំងអស់ឱ្យកាន់តែប្រសើរឡើងទៅក្នុងសេដ្ឋកិច្ចពិភពលោក។[៣២]

[31] Dominic Kelly, 'The International Chamber of Commerce' (2005) 10(2) New Political Economy 259.
[32] Ibid.

ឯកសារសំខាន់ៗរបស់ ICC ក្នុងការបង្កើត គម្រូកិច្ចសន្យានិងខសន្យា និងវិធានទន់ (Soft Law) ដូចខាងក្រោម៖

១. **វិធានក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ៖** Uniform Rules for Demand Guarantees 758, International Standby Practices 98, Uniform Customs and Practice for Documentary Credits 600

២. **កិច្ចសន្យាគម្រូ៖** International Sale Contract, Commercial Agency Contract, Distributorship Contract, Confidentiality Agreement, Mergers & Acquisitions Contract

៣. **ខសន្យាគម្រូ៖** Force Majeure Clause, Hardship Clause, Arbitration Clause

៤. **វិធានអនុលោមភាព និងការប្រឆាំងអំពើពុករលួយ៖** Rules on Combating Corruption, Whistleblowing Guidelines, Antitrust Compliance Toolkit

## ៣.៣ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យពាណិជ្ជកម្មកម្ពុជា

វិស័យពាណិជ្ជកម្ម គឺជាវិស័យដ៏សំខាន់មួយ ក្នុងការធ្វើឱ្យប្រសើរឡើងនូវផលិតកម្ម កម្រិតចំណូល កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍរបស់កម្ពុជា។ ក្រសួងពាណិជ្ជកម្ម បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវច្បាប់និងលិខិតបទដ្ឋានគតិយុត្ត កម្មវិធីគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យពាណិជ្ជកម្ម មានជាអាទិ៍ ការពង្រឹងលើកស្ទួយផលិតកម្ម ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងការនាំចេញតាមរយៈការធ្វើពិពិធកម្មទីផ្សារ សំដៅជំរុញកំណើន និងបង្កើនល្បឿនសមាហរណកម្មសេដ្ឋកិច្ច ពាណិជ្ជកម្មតំបន់ និងពិភពលោក។ ក្នុងដំណើរនៃកិច្ចខិតខំប្រឹងប្រែងកែទម្រង់ក្នុងវិស័យពាណិជ្ជកម្មទាំងក្នុងនិងក្រៅស្រុក ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ សំខាន់ៗជាច្រើន ក្នុងវិស័យពាណិជ្ជកម្មត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ដូចមានក្នុងឧបសម្ព័ន្ធទី៤។

បន្ថែមពីនេះ រាជរដ្ឋាភិបាលបានចាត់ទុកវិស័យឯកជន ជាកម្លាំងចលករយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ និងបានខិតខំសម្របសម្រួលនិងបង្កលក្ខណៈងាយស្រួលដល់វិស័យឯកជន ក្នុងការបោះទុនវិនិយោគ លើកទឹកចិត្តនិងគាំទ្រដល់ការបណ្តាក់ទុនវិនិយោគ តាមរយៈការអនុម័តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ២០២១ និងជំរុញការកែលម្អបរិយាកាសធុរកិច្ចផ្សេងៗ។ លើសពីនេះការតាក់តែង និងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានប្រកបដោយគុណភាពនិងប្រសិទ្ធភាព គឺជាកត្តាសំខាន់បំផុត ដើម្បីបង្កលក្ខណៈងាយស្រួល ទំនុកចិត្ត និងភាពជឿជាក់លើការធ្វើពាណិជ្ជកម្ម ធុរកិច្ច ឬការវិនិយោគ។ ក្នុងស្មារតីនេះ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យពាណិជ្ជកម្ម គប្បីប្រមូលផ្តុំឱ្យមានលក្ខណៈពេញលេញ ប្រទាក់ក្រឡាសង្គតិភាព និងឥតខ្វះចន្លោះ ជាមួយនឹងការកំណត់នូវមុខងារភារកិច្ចរបស់ស្ថាប័ន ក្នុងជីវភាពនៃប្រព័ន្ធតួអង្គតែមួយ ដើម្បីត្រៀមចាកចេញដោយរលូន ពីចំណាត់ថ្នាក់ប្រទេសមានការអភិវឌ្ឍតិចតួច

ដែលមានគោលដៅកាត់បន្ថយ ឬ លុបបំបាត់ផលប៉ះពាល់អវិជ្ជមាន ដែលកើតចេញពីការបាត់បង់ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និង វិធានការជំនួយអន្តរជាតិនានា ក៏ដូចជា ការធានាបាននូវចីរភាពនៃការអភិវឌ្ឍក្រោយការចាកចេញ នៅឆ្នាំ២០២៩។

## ៣.៤ ការសិក្សាស្រាវជ្រាវពីក្រមពាណិជ្ជកម្មពីប្រទេសអភិវឌ្ឍ និងប្រទេសដែលមានប្រព័ន្ធច្បាប់ស្រដៀងនឹងកម្ពុជា

| **សហរដ្ឋអាមេរិក**<br>Uniform Commercial Code | | **ប្រទេសបារាំង**<br>Code de Commerce | | **ប្រទេសអាល្លឺម៉ង់**<br>Handelsgesetz buch-HGB | | **ប្រទេសជប៉ុន**<br>Code of Commerce of Japan | |
|---|---|---|---|---|---|---|---|
| ១. | បទប្បញ្ញត្តិទូទៅ | ១. | បទប្បញ្ញត្តិទូទៅនៃពាណិជ្ជកម្ម | ១. | ទម្រង់សហគ្រាសពាណិជ្ជកម្ម | ១. | បទប្បញ្ញត្តិទូទៅ |
| ២. | ការលក់ទិញ | ២. | ទម្រង់នៃសហគ្រាស | ២. | ក្រុមហ៊ុនសហកម្មសិទ្ធិ និងសហកម្មសិទ្ធិករកំបាំងមុខ | ២. | ក្រុមហ៊ុន |
| ៣. | ភតិសន្យា | ៣. | ទម្រង់នៃការលក់ទិញ និងការផ្តាច់មុខ | ៣. | កំណត់ត្រាពាណិជ្ជកម្ម | ៣. | ប្រតិបត្តិការពាណិជ្ជកម្ម |
| ៤. | ឧបករណ៍ជួញដូរបាន | ៤. | សេរីភាពនៃតម្លៃលក់ និងការប្រកួតប្រជែង | ៤. | ប្រតិបត្តិការពាណិជ្ជកម្ម | ៤. | វិក័យបត្រ |
| ៥. | ប្រាក់បញ្ញើ | ៥. | ឧបករណ៍ជួញដូរបាន និងកិច្ចធានា | ៥. | ពាណិជ្ជកម្មតាមផ្លូវទឹក | ៥. | ច្បាប់ពាណិជ្ជកម្មតាមផ្លូវទឹក |
| ៦. | ការផ្ទេរប្រាក់ | ៦. | ផលលំបាកក្នុងអាជីវកម្ម | | | | |
| ៧. | លិខិតឥណទាន | ៧. | តុលាការពាណិជ្ជកម្ម និងសភាពាណិជ្ជកម្ម | | | | |
| ៨. | ការលក់ដុំ | ៨. | វិជ្ជាជីវៈដែលស្ថិតក្រោមការគ្រប់គ្រងពិសេស | | | | |
| ៩. | ឯកសារបញ្ជាក់កម្មសិទ្ធិ | ៩. | បទប្បញ្ញត្តិអនុវត្តលើទឹកដីក្រៅយុត្តាធិកា | | | | |
| ១០. | ការវិនិយោគមូលបត្រ | | | | | | |
| ១១. | ប្រតិបត្តិការដែលមានកិច្ចធានា | | | | | | |

# ៤. ក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

## ៤.១ និយមន័យនីតិពាណិជ្ជកម្មសម្រាប់កម្ពុជា

នីតិពាណិជ្ជកម្ម ត្រូវបានកំណត់និយមន័យខុសៗគ្នា ទៅតាមប្រព័ន្ធច្បាប់របស់ប្រទេសនីមួយៗ សម្រាប់យកមកអនុវត្តក្នុងការដឹកនាំ និងគ្រប់គ្រងច្បាប់ពាណិជ្ជកម្ម។ នៅក្នុងបទប្បញ្ញត្តិទូទៅនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជាបានកំណត់នូវនិយមន័យពាណិជ្ជករ គឺជារូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលធ្វើពាណិជ្ជកិច្ច ហើយដែលយកពាណិជ្ជកិច្ចនេះជា មុខរបរខ្លួនជាប្រចាំ។ ពាណិជ្ជកិច្ច ជាសកម្មភាពទិញ លក់ទំនិញ ឬសេវាដែលត្រូវបានអនុវត្តជាប្រចាំក្នុងគោលដៅធ្វើការដោះដូរ និងស្វែងរកចំណេញ។ ច្បាប់នេះចាត់ទុកថាជាពាណិជ្ជកិច្ចរាល់សកម្មភាព ដែលមានចែងជាអាទិ៍ដូចខាងក្រោម៖

- ការទិញដើម្បីលក់ទៅវិញ គិតបញ្ចូលទាំងក្នុងវិស័យអចលនទ្រព្យ
- រាល់សកម្មភាពនៃសហគ្រាសជួល សហគ្រាសការណកម្ម សហគ្រាសយកកម្រៃជើងសា សហគ្រាសដឹកជញ្ជូន សហគ្រាសបោះពុម្ពផ្សាយ និងសេវាដទៃទៀត
- ប្រតិបត្តិការនៃធនាគារប្តូររូបិយវត្ថុ
- ការផ្តល់សេវាអន្តរការ សេវាទីភ្នាក់ងារ ការិយាល័យសម្របសម្រួលកិច្ចការសេវាវប្បធម៌ និងការចាត់ចែងនូវទស្សនីយភាព ជាសាធារណៈ
- សហគ្រាសសំណង់ ការទិញ ឬការជួលនាវាដឹកជញ្ជូនក្នុងប្រទេស ឬក្រៅប្រទេស ការដឹកជញ្ជូន និងការផ្ញើ បញ្ជូនតាមផ្លូវគោក ផ្លូវទឹក ឬផ្លូវអាកាស
- ការធានារ៉ាប់រងគ្រប់ប្រភេទ
- អាជីវកម្មនេសាទ អាជីវកម្មព្រៃឈើ និងរ៉ែ។

កម្ពុជា មានប្រព័ន្ធច្បាប់កម្ពុជា ប្រកបដោយគុណតម្លៃជាប្រវត្តិសាស្ត្ររបស់ខ្លួនផង និងគុណតម្លៃសាកលផង ដោយបានកំណត់នូវចក្ខុវិស័យច្បាស់លាស់ក្នុងការកែទម្រង់ច្បាប់ ឆ្ពោះទៅការកសាងបូរណភាពនៃប្រព័ន្ធច្បាប់ និងចីរភាពវប្បធម៌នីតិរដ្ឋ។ ក្នុងស្មារតីនេះ នីតិ ក្នុងវិស័យពាណិជ្ជកម្ម ឬនីតិពាណិជ្ជកម្មក៏នឹងត្រូវកំណត់នូវនិយមន័យ និងធាតុផ្សំ សម្រាប់បរិការណ៍កម្ពុជា ហេតុនេះអគ្គលេខាធិការដ្ឋាន គ.ក.ច. សាកល្បងកំណត់នូវ នីតិពាណិជ្ជកម្មកម្ពុជា ក្នុងរូបភាពដូចខាងក្រោម៖

- ជាបណ្តុំនៃវិធានគតិយុត្តដែលគ្របដណ្តប់ក្នុងការគ្រប់គ្រង និងប្រតិបត្តិការពាណិជ្ជកម្ម
- ជាបណ្តុំនៃវិធានគតិយុត្តដែលគ្របដណ្តប់ក្នុងទំនាក់ទំនងពាណិជ្ជកម្ម រួមមានទាំងអាជីវកម្ម និងអាជីវកម្ម អាជីវកម្មនិងអ្នកប្រើប្រាស់ចុងក្រោយ
- ជាបណ្តុំនៃវិធានគតិយុត្តដែលគ្របដណ្តប់ដល់ស្ថាប័នស្វែងរកប្រាក់ចំណេញ សកម្មភាពសេដ្ឋកិច្ច ធុរកិច្ច និងការវិនិយោគ

- ជាបណ្តុំនៃវិធានគតិយុត្តទាំងឡាយណាដែលគ្រប់គ្រងលើប្រតិបត្តិការពាណិជ្ជកម្ម និង/ឬ ទំនាក់ទំនងធុរកិច្ច ដែលបញ្ញត្តិអំពីសិទ្ធិ កាតព្វកិច្ច និង/ឬ ការទទួលខុសត្រូវរបស់រូបវន្តបុគ្គលឬនីតិបុគ្គលដែលប្រកបរបរពាណិជ្ជកម្ម។
- នីតិពាណិជ្ជកម្ម ជាសាខានៃនីតិឯកជន ពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម ដោយមិនគ្របដណ្តប់ដល់នីតិផ្សេងៗ ដែលជាសាខានៃនីតិសាធារណៈ (ហិរញ្ញវត្ថុ ពន្ធដារ គយ) នោះទេ។

## ៤.២ ក្របខ័ណ្ឌនៃក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

ប្រព័ន្ធច្បាប់ពាណិជ្ជកម្មកម្ពុជាបច្ចុប្បន្ន ស្ថិតនៅក្រោមច្បាប់ពិសេសផ្សេងៗគ្នាជាច្រើន(ដូចមានក្នុងឧបសម្ព័ន្ធទី៣) និងមានទំនាក់ទំនងជាមួយក្រមរដ្ឋប្បវេណីក្នុងនាមជាច្បាប់ទូទៅ និងច្បាប់ពិសេស។ ក្រមរដ្ឋប្បវេណីដើរតួនាទីជាច្បាប់ទូទៅនៃនីតិឯកជន ដែលគ្រប់គ្រងលើទំនាក់ទំនគតិយុត្តផ្នែករដ្ឋប្បវេណីនៃទំនាក់ទំនងទ្រព្យសម្បត្តិ និងទំនាក់ទំនងញាតិលើកលែងតែមានការកំណត់ផ្សេងក្នុងច្បាប់ពិសេស។ នៅក្នុងអនុវត្តជាក់ស្តែង ក្រមរដ្ឋប្បវេណីបានក្លាយជាក្របខ័ណ្ឌគតិយុត្តគោលសម្រាប់ដោះស្រាយបញ្ហាធុរកិច្ចជាច្រើន រួមមាន កិច្ចសន្យា កាតព្វកិច្ច កម្មសិទ្ធិ ការទទួលខុសត្រូវ អាណត្តិ និងអាជ្ញាយុកាលនៃសិទ្ធិ និងកាតព្វកិច្ចជាដើម។ រីឯ ច្បាប់ក្នុងវិស័យពាណិជ្ជកម្មកម្ពុជា ដើរតួនាទីជាច្បាប់ពិសេស ដែលគ្រប់គ្រងលើតួអង្គធុរកិច្ច ឬប្រតិបត្តិការជាក់លាក់ ដូចជា ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលត្រូវបានអនុវត្តចំពោះក្រុមហ៊ុនសហកម្មសិទ្ធិនិងក្រុមហ៊ុនមូលធនដែលធ្វើអាជីវកម្មនៅកម្ពុជា ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងការចុះបញ្ជីពាណិជ្ជកម្ម ដែលប្រើប្រាស់និយមន័យ “ពាណិជ្ជករ” និង “ពាណិជ្ជកម្ម” ដើម្បីកំណត់សកម្មភាពពាណិជ្ជកម្ម និងការចុះបញ្ជីពាណិជ្ជកម្ម និងច្បាប់ផ្សេងទៀត (ដូចមានក្នុងឧបសម្ព័ន្ធទី៣)។

ក្នុងន័យនេះ បញ្ហាស្នូលមិនស្ថិតនៅលើច្បាប់ក្នុងវិស័យពាណិជ្ជកម្មកម្ពុជាមានចំនួនច្រើនឬការកំណត់និយមន័យនៃពាក្យថា “ពាណិជ្ជកម្ម” នោះទេ ប៉ុន្តែស្ថិតនៅលើភាពច្បាស់លាស់នៃក្រមពាណិជ្ជកម្មក្នុងការបង្កើតឱ្យមានប្រព័ន្ធរួមសម្រាប់គ្រប់គ្រងលើទំនាក់ទំនងពាណិជ្ជកម្ម និងការកំណត់វិសាលភាពរវាងក្រមពាណិជ្ជកម្ម និងច្បាប់ពាក់ព័ន្ធផ្សេងទៀត ។

ក្រមពាណិជ្ជកម្ម មិនបង្កើតឡើងក្នុងលក្ខណៈជាច្បាប់បន្ថែមនោះទេ ប៉ុន្តែជាបញ្ញត្តិគ្រឹះដែលកំណត់អំពីទំនាក់ទំនង វិសាលភាព និងកម្រិតឋានុក្រមរវាងក្រមនេះ និងច្បាប់ក្នុងវិស័យពាណិជ្ជកម្មផ្សេងទៀតដែលមានស្រាប់ និងបំពេញបន្ថែម ដើម្បីធានាបាននូវសមានគតិភាព (coherence) និងបង្កើតបានជាប្រព័ន្ធមួយដែលបម្រើផលប្រយោជន៍ ដល់អាជីវករ ពាណិជ្ជករ ធុរជន អ្នកវិនិយោគជាដើម។ ការកំណត់វិសាលភាព លើសពីការកំណត់និយមន័យនៃពាណិជ្ជកម្ម គឺដើម្បីធានានូវ៖ (១)ភាពច្បាស់លាស់នៃច្បាប់(Legal Certainty)សម្រាប់ចៅក្រម អ្នកអនុវត្តច្បាប់ អ្នកប្រកបវិជ្ជាជីវៈច្បាប់ក្នុងការជ្រើសរើសវិធានណាមួយយកមកអនុវត្ត វិនិយោគិន និងអ្នកសិក្សា (២)ជៀសវាងការចែងបទប្បញ្ញត្តិស្ទួនគ្នារវាងច្បាប់ពីរដែលដោះស្រាយលើបញ្ហាតែមួយ និង(៣)ចៀសវាងភាពមិនស៊ីសង្វាក់គ្នារវាងបទប្បញ្ញត្តិដែលធ្វើឱ្យរាំងស្ទះដល់ប្រតិបត្តិការពាណិជ្ជកម្ម។

ដើម្បីចៀសវាងបញ្ហាទាំងនេះ អគ្គលេខាធិការដ្ឋាន គ.ក.ច. បានរៀបចំនូវសំណួរដើម្បីពិចារណាលើសមាសធាតុនៃវិសាលភាពក្រមពាណិជ្ជកម្មចំនួន ៤ រួមមាន៖

១. **វិសាលភាពផ្អែកលើកម្មវត្ថុ(Object)៖** សំដៅលើប្រភេទនៃប្រតិបត្តិការពាណិជ្ជកម្មនិងទំនាក់ទំនងគតិយុត្តដែលស្ថិតនៅក្រោមក្រមពាណិជ្ជកម្ម។ តើក្រមពាណិជ្ជកម្មកម្ពុជា គួរកំណត់ត្រឹមតែការគ្រប់គ្រងលើពាណិជ្ជកម្មជាទូទៅ ឬផ្អែកតាមការអនុវត្តជាក់ស្តែងនៃសកម្មភាពពាណិជ្ជកម្ម? តើវិសាលភាពនេះ គួរគ្របដណ្តប់លើប្រតិបត្តិការ និងទំនាក់ទំនងដែលកើតចេញពីសកម្មភាពណាខ្លះ? (ឧទាហរណ៍ ការលក់ទំនិញ ការផ្គត់ផ្គង់សេវាកម្ម ការចែកចាយ ភ្នាក់ងារពាណិជ្ជកម្ម កាតព្វកិច្ចទូទាត់ កិច្ចសន្យាធុរកិច្ច និងការដោះដូរផ្សេងៗក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ) តើទំនាក់ទំនងណាខ្លះដែលមិនស្ថិតនៅក្រោមបទប្បញ្ញត្តិនៃក្រមពាណិជ្ជកម្ម? (ឧទាហរណ៍ ទំនាក់ទំនងអចលនទ្រព្យ ការបន្តមរតក ពន្ធដារ គយ បទប្បញ្ញត្តិការងារ និងវិស័យហិរញ្ញវត្ថុដែលមានបទប្បញ្ញត្តិដោយឡែក)

២. **វិសាលភាពផ្អែកលើបុគ្គល៖** សំដៅលើប្រភេទនៃបុគ្គល ឬតួអង្គដែលត្រូវអនុវត្តនិងគ្រប់គ្រងដោយក្រមពាណិជ្ជកម្ម។ តើវិសាលភាពនៃក្រមគួរគ្របដណ្តប់លើបុគ្គលណាខ្លះ (ឧទាហរណ៍ រូបវន្តបុគ្គល សហគ្រាសឯកបុគ្គល សហក្រុមហ៊ុន ក្រុមហ៊ុន សហគ្រាសធុនតូចនិងមធ្យម (SMEs) និងក្រុមហ៊ុនបរទេសដែលធ្វើធុរកិច្ចនៅកម្ពុជា)។ ទោះបីជាការចុះបញ្ជីមានសារៈសំខាន់សម្រាប់ការអនុលោមតាមច្បាប់ក៏ដោយ តើក្រមគួរកំណត់លក្ខខណ្ឌផ្សេងទៀតដែលពន្លាតសុពលភាពនៃការអនុវត្តក្រមលើស្ថានភាពផ្សេងទៀតដែរឬទេ? (ឧទាហរណ៍ បុគ្គលដែលចុះបញ្ជី និង/ឬបុគ្គលដែលធ្វើអាជីវកម្មមិនចុះបញ្ជី និង/ឬបុគ្គលដែលចុះបញ្ជីតែមិនធ្វើអាជីវកម្ម)

៣. **វិសាលភាពនៃដែនដី(Territorial/external Scope)៖** សំដៅលើស្ថានភាពភូមិសាស្ត្រ និងយុត្តាធិការដែលក្រមនេះត្រូវអនុវត្ត។ តើវិសាលភាពនៃក្រមពាណិជ្ជកម្មគ្របដណ្តប់លើប្រតិបត្តិការពាណិជ្ជកម្មធ្វើឡើងតាមរយៈបច្ចេកវិទ្យា(online) និង/ឬមានលក្ខណៈឆ្លងដែន(cross-border) ដែរឬទេ? តើក្រមពាណិជ្ជកម្មដែលអនុវត្តលើដែនដីកម្ពុជា ផ្សាភ្ជាប់ទំនាក់ទំនងដោយរបៀបណាទើបមានអានុភាពអនុវត្តក្នុងដែនដីប្រទេសដទៃ? ផ្អែកលើទីកន្លែងប្រកបអាជីវកម្ម ទីកន្លែងអនុវត្តកាតព្វកិច្ច ទីកន្លែងប្រគល់ទំនិញ ទីកន្លែងទូទាត់ប្រាក់ ឬកន្លែងដែលរងផលប៉ះពាល់ដោយប្រតិបត្តិការទាំងនោះ?

៤. **វិសាលភាពផ្អែកបច្ចេកវិទ្យា (Technological Scope)៖** សំដៅលើសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច។ តើក្រមពាណិជ្ជកម្មអនុវត្តលើពាណិជ្ជកម្ម ដែលធ្វើឡើងតាមរយៈប្រព័ន្ធឌីជីថល (ដូចជា E-commerce) ហត្ថលេខាឬកិច្ចសន្យាអេឡិចត្រូនិច្ច (E-contract, E-signature)ឬប្រព័ន្ធផ្សេងទៀតដែរឬទេ?

### ៤.៣ វិធីសាស្ត្រនៃការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

ការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា ប្រើប្រាស់វិធីសាស្ត្រចម្រុះ ដោយចាប់ផ្តើមចេញពីការប្រមូលផ្តុំ ការចងក្រង រហូតឈានដល់ការរៀបចំចេញជាសេចក្តីព្រាងក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា។ ដើម្បីធានានូវគុណភាព ភាពគ្រប់ជ្រុងជ្រោយ និងមានសង្គតិភាពជាមួយប្រព័ន្ធច្បាប់ស៊ីវិល (Civil Law) និងបទដ្ឋានគតិយុត្តពាណិជ្ជកម្មអន្តរជាតិ ការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា នឹងត្រូវបែងចែកជា៨ជំហាន (ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២)។

### ៤.៤ សេចក្តីព្រាងមាតិកានៃក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

ដើម្បីធានានូវសង្គតិភាព បូរណភាព និងនីត្យានុភាព នៃការតាក់តែងសេចក្តីព្រាង និងការបកស្រាយសម្រាប់អនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យពាណិជ្ជកម្ម ស្របតាមដំណាក់កាលទី២ នៃក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល អគ្គលេខាធិការដ្ឋាន គ.ក.ច. បានសាកល្បងរៀបចំជាសេចក្តីព្រាងមាតិកាសម្រាប់ក្រមពាណិជ្ជកម្មកម្ពុជា តាមវដ្តនៃពាណិជ្ជកម្ម ដោយកំណត់១០គន្លឹ (គន្លឹ មាតិកា ជំពូក ផ្នែក) រួមមាន បទប្បញ្ញត្តិទូទៅ វិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម និងសហគ្រាសពាណិជ្ជកម្ម ម៉ាកនិងពាណិជ្ជនាមនិងការប្រកួតប្រជែងមិនស្មោះត្រង់ ប្រតិបត្តិការពាណិជ្ជកម្ម ការប្រកួតប្រជែងនិងកិច្ចការពារអ្នកប្រើប្រាស់ ស្ថានភាពលំបាកក្នុងពាណិជ្ជកម្ម ការដោះស្រាយវិវាទ ទោសប្បញ្ញត្តិ អន្តរប្បញ្ញត្តិ និងអវសានប្បញ្ញត្តិ។ បន្ថែមពីនេះ ដើម្បីធានាឱ្យមានការឯកភាពលើខ្លឹមសារ សម្រាប់ការបកស្រាយ ក្រមពាណិជ្ជកម្មកម្ពុជា ក៏តម្រូវឱ្យមានភ្ជាប់នូវសន្ទានុក្រម និងសេចក្តីពន្យល់ក្រម (តាមការចាំបាច់)ផងដែរ (ដូចមានក្នុងឧបសម្ព័ន្ធទី៦)។

## ៥. ការគ្រប់គ្រងធនធាន

ដើម្បីចូលរួមដោះស្រាយបញ្ហាសេដ្ឋកិច្ច សង្គម ការអភិវឌ្ឍក្នុងយុគសម័យឌីជីថល និងការប្រែប្រួលមិនអាចប៉ាន់ស្មានបាននៃសង្គ្រាមពិភពលោក វិធានគតិយុត្តក្នុងវិស័យពាណិជ្ជកម្ម ត្រូវបានគិតគូរឡើងវិញ ក្នុងក្របខ័ណ្ឌនៃការរៀបចំជាលក្ខណៈក្រមពាណិជ្ជកម្ម ដែលជាចំណែកមួយនៃប្រព័ន្ធច្បាប់ ដើម្បីបង្កើតបរិស្ថានរួមមួយជួយសម្រួល និងដោះស្រាយបញ្ហានៃការធ្វើពាណិជ្ជកម្ម ធុរកិច្ច និងទាក់ទាញវិនិយោគ ពិសេសការសម្រួលនីតិវិធី ការកាត់បន្ថយថ្លៃដើម ពេលវេលា និងការបង្កើតបរិយាកាសប្រកួតប្រជែងដោយស្មើភាព ការងារ ការបង្កើនប្រាក់ចំណូល និងតម្លៃបន្ថែម ព្រមទាំងការជំរុញកំណើនសេដ្ឋកិច្ចគ្រួសារ និងប្រទេសជាតិ។ ក្នុងស្មារតីនេះ កត្តាធនធានមនុស្ស និងហិរញ្ញវត្ថុ ត្រូវបានគិតគូរយ៉ាងយកចិត្តទុកដាក់ និងម៉ត់ចត់បំផុត។

### ៥.១ ធនធានមនុស្ស

គ.ក.ច. ជាសេនាធិការជូនរាជរដ្ឋាភិបាល ក្នុងការផ្តួចផ្តើមនិងលើកសំណើជូនប្រមុខរាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងកិច្ចការកែទម្រង់ច្បាប់។ ក្នុងស្មារតីនេះ គ.ក.ច. នឹងលើកសំណើជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីបង្កើតក្រុមការងារជាពីរកម្រិត គឺកម្រិតនយោបាយ និងកម្រិតបច្ចេកទេស ដើម្បីរៀបចំក្រមពាណិជ្ជកម្ម

ដោយសម្រិតសម្រាំងសមាសភាពជាអ្នកជំនាញច្បាប់កម្រិតខ្ពស់ អ្នកជំនាញគោលនយោបាយ អ្នកជំនាញសេដ្ឋកិច្ច អ្នកជំនាញពាណិជ្ជកម្ម មកពីក្រសួង ស្ថាប័នពាក់ព័ន្ធចំណុះរាជរដ្ឋាភិបាល និងស្ថាប័នឯកជន និងអ្នកជំនាញការអន្តរជាតិ (ក្នុងករណីចាំបាច់)។

អគ្គលេខាធិការដ្ឋាន គ.ក.ច. មានតួនាទីជាសេនាធិការជូន គ.ក.ច. លើការសិក្សា ស្រាវជ្រាវ និងរៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពសម្រាប់កម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ អគ្គលេខាធិការដ្ឋាន គ.ក.ច. សហការជាមួយលេខាធិការដ្ឋាន គ.ផ.គ.ព. ដើម្បីរៀបចំទស្សនាទាន សម្របសម្រួល តាក់តែង បូកសរុបខ្លឹមសារសម្រាប់ក្រមពាណិជ្ជកម្ម និងរៀបចំរបាយការណ៍និងឯកសារពាក់ព័ន្ធនានា ជូន គ.ក.ច. និងរាជរដ្ឋាភិបាល។

### ៥.២ ធនធានហិរញ្ញវត្ថុ

គម្រោងរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា ត្រូវការចំណាយពេលវេលានិងធនធានច្រើន ដូច្នេះគម្រោងនេះនឹងត្រូវសិក្សាស្នើសុំ ក្នុងកញ្ចប់ថវិការដ្ឋដោយឡែកក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាល។ អគ្គលេខាធិការដ្ឋាន គ.ក.ច. ជាអ្នកទទួលបន្ទុករៀបចំគម្រោងថវិកា និងអនុវត្តថវិកាតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។ បន្ថែមពីនេះ អគ្គលេខាធិការដ្ឋាន គ.ក.ច. អាចស្វែងរកជំនួយបច្ចេកទេស និងជំនួយហិរញ្ញវត្ថុពីបណ្តាដៃគូអភិវឌ្ឍន៍ ប្រទេសជាមិត្ត និងស្ថាប័នឯកជននានា ដើម្បីគាំទ្រក្នុងដំណើរការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា ឱ្យមានភាពគ្រប់ជ្រុងជ្រោយ ប្រកបដោយគុណភាព និងប្រសិទ្ធភាពដែលអាចដោះស្រាយបាននូវបញ្ហាចំពោះមុខផង និងបញ្ហានាពេលអនាគតផង។

## ៦. ផែនការសកម្មភាពនិងក្របខ័ណ្ឌពេលវេលា

ផែនការសកម្មភាពនៃការរៀបចំក្រមពាណិជ្ជកម្ម ត្រូវបានគិតគូរបែងចែកជាបីដំណាក់កាល ដូចខាងក្រោម (ដូចមានក្នុងតារាងឧបសម្ព័ន្ធទី៥)៖

- **ដំណាក់កាលទី១៖** ការរៀបចំទស្សនាទានស្តីពីការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា គ្រោងប្រើរយៈពេល ៨ខែ រាប់ចាប់ពីខែវិច្ឆិកា ឆ្នាំ២០២៥ ដល់ខែមិថុនា ឆ្នាំ២០២៦ លើសកម្មភាពការងារចម្បងៗដូចជា ការរៀបចំទស្សនាទានបឋមស្តីពីគម្រោងរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា កិច្ចប្រជុំពិគ្រោះយោបល់ ដែលបានរៀបចំឡើងកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៦ ដឹកនាំដោយ **ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាន គ.ក.ច.** ការបង្កើតក្រុមការងាររៀបចំទស្សនាទាន ការសិក្សាស្រាវជ្រាវឧត្តមានុវត្តន៍អន្តរជាតិពាក់ព័ន្ធនឹងវិធីសាស្ត្រនៃការធ្វើក្រម ទស្សនកិច្ចសិក្សា ការរៀបចំទស្សនាទាន សិក្ខាសាលាពិគ្រោះយោបល់ ដើម្បីកំណត់ពីតម្រូវការនៃការរៀបចំក្រម កំណត់ពីវិសាលភាព វិធីសាស្ត្រ ដំណើរការ និងសេចក្តីណែនាំការងារលម្អិតតាមជំហានជាបន្តបន្ទាប់ និងសេចក្តីព្រាងមាតិកានៃក្រម។

- **ដំណាក់កាលទី២៖** ការរៀបចំក្រមពាណិជ្ជកម្មកម្ពុជា គ្រោងចំណាយពេល **៣៦ខែ** សម្រាប់ការងារសំខាន់ៗដូចជា៖ ការបង្កើតក្រុមការងារកម្រិតរាជរដ្ឋាភិបាលស្តីពីការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា ការបែងចែកក្រុមការងារបច្ចេកទេសសម្រាប់ប្រមូល បែងចែកអត្ថបទគតិយុត្តជាធរមាន វិភាគចន្លោះខ្វះខាតអត្ថបទច្បាប់និងតម្រូវការបំពេញបន្ថែម រៀបចំមាតិកានិងខ្លឹមសារ និងក្រុមការងារសម្របសម្រួលនិងបូកសរុប។ សកម្មភាពដែលត្រូវចាប់ផ្តើមដំបូងគឺប្រមូលផ្តុំ (Consolidation) ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យពាណិជ្ជកម្មឱ្យអស់ (ទាំងនិរាករណ៍ ទាំងធរមាន ទាំងសេចក្តីព្រាង) បន្ទាប់មកធ្វើការសម្អាត តាមរយៈវិធីសាស្ត្រ ចងក្រង (Compilation) នូវច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងធ្វើចំណាត់ថ្នាក់អត្ថបទនៃបទដ្ឋានគតិយុត្តប្រកបដោយរចនាសម្ព័ន្ធជាក់លាក់ (វិធីសាស្ត្ររៀបចំលម្អិតមានក្នុងឧបសម្ព័ន្ធទី២)។ ជំហានបន្តគឺរៀបចំមាតិកា រៀបចំរចនាសម្ព័ន្ធនៃអត្ថបទគតិយុត្ត ខ្លឹមសារ តាមវដ្តពាណិជ្ជកម្ម ដោយអាចនិរាករច្បាប់និងលិខិតបទដ្ឋានគតិយុត្ត បញ្ចូលខ្លឹមសារថ្មី បំពេញបន្ថែមចំណុចខ្វះខាត ឬពន្យល់ចំណុចស្រពិចស្រពិលជាដើម ដោយភ្ជាប់នូវសន្ទានុក្រម និងសេចក្តីពន្យល់ក្រមផងដែរ។ ការពិគ្រោះយោបល់ទាំងកម្រិតចង្អៀតនិងជាសាធារណៈ ក៏ត្រូវគិតគូររៀបចំច្រើនលើកផងដែរ។
- **ដំណាក់កាលទី៣៖** ដំណើរការការអនុម័ត និងការផ្សព្វផ្សាយក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា គ្រោងចំណាយ**ពេល១២ខែ**៖ ក្រុមការងារអន្តរក្រសួង នៃរាជរដ្ឋាភិបាល នឹងរៀបចំសេចក្តីព្រាងក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា ដោយឆ្លងកាត់ក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គម និងវប្បធម៌ កិច្ចប្រជុំអន្តរក្រសួង និងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី។ បន្ទាប់ពីទទួលបានការពិនិត្យនិងសម្រេចដោយគណៈរដ្ឋមន្ត្រី សេចក្តីព្រាងក្រម នឹងត្រូវដាក់ចូលគណៈកម្មការអចិន្ត្រៃយ៍ និងគណៈកម្មការជំនាញនៃរដ្ឋសភា។ អត្ថបទសេចក្តីព្រាងក្រម ដែលរដ្ឋសភាបានអនុម័តលើកដំបូងរួចហើយ នឹងត្រូវបញ្ជូនទៅព្រឹទ្ធសភា ពិនិត្យ និងឱ្យយោបល់។ ក្រមដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យ ចប់សព្វគ្រប់រួចហើយ នឹងត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើជាការប្រញាប់ ឬធម្មតា ស្របតាមនីតិវិធីជាធរមាន។ ក្រមដែលព្រះមហាក្សត្រ ទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ច និងបោះពុម្ពផ្សព្វផ្សាយ (Soft&Hard Copy) នៅទូទាំងប្រទេសស្របតាមលិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមាន។ បន្ថែមពីនេះក្រមពាណិជ្ជកម្ម នឹងត្រូវផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមរយៈសិក្ខាសាលាផ្សព្វផ្សាយ តាមរយៈបណ្តាញសង្គម និងទាំងក្នុងកម្រិតជាតិនិងអន្តរជាតិ។

## ឧបសម្ព័ន្ធទី១ វិធីសាស្ត្រក្នុងការរៀបចំក្រមនៅកម្ពុជា

### ១.១ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី

ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ត្រូវបានរៀបចំឡើងក្រោមជំនួយរបស់ប្រទេសជប៉ុនតាមរយៈទីភ្នាក់ងារប្រតិបត្តិការអន្តរជាតិជប៉ុន ( Japan International Co-operation Agency - JICA) ដែលម្ចាស់ជំនួយក្នុងការរៀបចំក្រម នៅក្នុងខែមីនា ឆ្នាំ១៩៩៩។ ជំនួយផ្នែកច្បាប់របស់ជប៉ុន បាននាំយកមូលដ្ឋានគ្រឹះនៃប្រព័ន្ធច្បាប់ស៊ីវិលរួមទាំងបច្ចេកទេសនៃការតាក់តែងច្បាប់ ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិដែលគាំទ្រដល់ការអនុវត្តក្រម សេចក្តីពន្យល់និងសេចក្តីកំណត់ក្រម។ ក្រមរដ្ឋប្បវេណី បានជួយជម្រុញដល់ការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា លើកម្ពស់ការយល់ដឹកផ្នែកច្បាប់ និងសម្រួលការបកស្រាយច្បាប់របស់ចៅក្រម មកកាន់កម្ពុជា ស្របពេលដែលកម្ពុជាមិនទាន់មានយុទ្ធសាស្ត្រ ឬសេចក្តីសម្រេចដែលមានតម្លៃជាច្បាប់ដែលអាចបកស្រាយឱ្យស្របនឹងគោលគំនិតនៃច្បាប់នោះបាន។

នៅក្នុងដំណើរការនៃការរៀបចំក្រមទាំងពីរនេះ ក្រុមការងារចំនួនពីរត្រូវបានបង្កើតឡើងដោយរួមមាន ក្រុមការងារកម្ពុជាសម្រាប់ក្រមរដ្ឋប្បវេណីនិងនីតិវិធីរដ្ឋប្បវេណី និងក្រុមការងារគាំទ្រការតាក់តែងសេចក្តីព្រាងក្រមរដ្ឋប្បវេណីនិងក្រមនីតិវិធីរដ្ឋប្បវេណីនៅប្រទេសជប៉ុន។[33] ក្រុមការងារកម្ពុជាសម្រាប់រៀបចំ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានបង្កើតឡើងដើម្បីបំពេញការងារចាំបាច់នៃដំណើរការនៃការតាក់តែងច្បាប់ និងបទប្បញ្ញត្តិបទប្បញ្ញត្តិ ក៏ដូចជាដំណើរការនៃការអនុម័តច្បាប់ ( process of legislation) អាចប្រព្រឹត្តទៅបានដោយរលូន។ ចំពោះក្រុមការងារគាំទ្រការតាក់តែងសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីនៅក្នុងប្រទេសជប៉ុន ត្រូវបានបង្កើតឡើងដើម្បីអនុវត្តការងារបច្ចេកទេស និងផ្តល់ការណែនាំ ឬការប្រឹក្សាបច្ចេកទេសចាំបាច់នានាដល់ក្រុមការងារកម្ពុជា ធ្វើឱ្យដំណើរការនៃការអនុម័តច្បាប់ និងការតាក់តែងច្បាប់នានាដែលពាក់ព័ន្ធនឹងក្រមទាំងនេះអាចប្រព្រឹត្តទៅបានដោយរលូន។

ក្រុមការងារគាំទ្រការតាក់តែងសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីនៅក្នុងប្រទេសជប៉ុន បានបង្កើតក្រុមការងារចំនួនពីរទៀត ដើម្បីរៀបចំសេចក្តីស្នើសម្រាប់សេចក្តីព្រាងច្បាប់ដោយក្នុងក្រុមនីមួយៗមានសមាជិកចំនួន ១០ រូប ដែលរួមមានអ្នកប្រាជ្ញច្បាប់ ចៅក្រម និងមន្ត្រីនៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវនៃក្រសួងយុត្តិធម៌។[34] ក្រុមទាំងពីរនេះ ត្រូវបានដឹកនាំនិងរៀបចំដោយ លោកសាស្ត្រាចារ្យ Morishima Akio ជាប្រធានក្រុមការងារទទួលបន្ទុកតាក់តែងក្រមរដ្ឋប្បវេណី និងលោកសាស្ត្រាចារ្យ Takeshita Morio ជាប្រធានក្រុមការងារទទួលបន្ទុកតាក់តែងក្រម

[33] Record of Discussions Between the Ministry of Justice of the Royal Government of Cambodia and Japan International Government of Cambodia and Japan International Cooperation Agency on The Extension of the term of the Japanese technical cooperation on legal and judicial Development Project (Phrase 2), Phnom Penh, 29 March 2007, part VI.

[34] NOP Kanharith, Legal Development in Cambodia before and after Japanese Assistance, page 4.

នីតិវិធីរដ្ឋប្បវេណី។ ការពិភាក្សាត្រូវបានធ្វើឡើងតាមរយៈការបកប្រែផ្ទាល់មាត់រវាងភាសាជប៉ុន និងភាសាខ្មែរ និងចៀសវាងការប្រើប្រាស់ភាសាទី៣ ដូចជាភាសាអង់គ្លេស ដើម្បីបង្ការការលាយឡំនូវទស្សនាទាននៃការបកស្រាយច្បាប់ខុសៗគ្នា ដូចជាច្បាប់របស់អង់គ្លេស ឬអាមេរិក និងដើម្បីសម្រួលដល់ការបញ្ជូនខ្លឹមសារនៃទស្សនាទានក្នុងសេចក្តីព្រាងច្បាប់ឱ្យបានត្រឹមត្រូវ។[35] ការបកប្រែពីភាសាជប៉ុនមកភាសាខ្មែរ ទាមទារឱ្យមានការពិនិត្យនិងផ្ទៀងផ្ទាត់ឡើងវិញលើសំណៅដើមជាភាសាជប៉ុន នៅក្នុងទិដ្ឋភាពបច្ចេកទេស ការអនុវត្តទ្រឹស្តីនិងក្នុងស្ថានភាពជាក់ស្តែង។ គោលបំណងសំខាន់នោះគឺធ្វើយ៉ាងណាឱ្យក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីក្លាយជាច្បាប់ដែលងាយស្រួលឱ្យកម្ពុជាអាចទទួល និងអាចអនុវត្តបាន តាមរយៈការបង្កើត និងការធ្វើវិសោធនកម្មសេចក្តីព្រាងក្រម ដោយការប្រមូលធាតុចូល និងមតិយោបល់របស់អ្នកវិជ្ជាជីវៈច្បាប់ និងចៅក្រម ដែលជាអ្នកយល់ដឹងច្បាស់អំពីស្ថានភាពនិងលក្ខខណ្ឌជាក់ស្តែងនៃសង្គមកម្ពុជា ហើយក៏ជាអ្នកដែលនឹងត្រូវទទួលបន្ទុកក្នុងការអនុវត្តក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីនេះផ្ទាល់។

ក្រមរដ្ឋប្បវេណី គឺជាមូលដ្ឋានច្បាប់ដ៏សំខាន់ដែលដើរតួនាទីក្នុងការអភិវឌ្ឍសង្គម និងជះឥទ្ធិពលដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ក៏ដូចជាប្រពៃណីទំនៀមទម្លាប់។ ក្រមរដ្ឋប្បវេណីកម្ពុជាត្រូវបានរៀបចំដោយយកគំរូតាមក្រមរដ្ឋប្បវេណីជប៉ុន ដោយមានបញ្ចូលនូវវិធានមួយចំនួនដែលដកស្រង់ចេញពីក្រមរដ្ឋប្បវេណីបារាំង និងអាល្លឺម៉ង់ និងបានគិតគូរលើច្បាប់អន្តរជាតិ ដើម្បីឱ្យមានភាពប្រទាក់ក្រឡាគ្នារវាងច្បាប់ជាតិនិងច្បាប់អន្តរជាតិ។[36] ជាពិសេស គឺវិធានដែលទាក់ទងនឹងច្បាប់កិច្ចសន្យា ដូចមាននៅក្នុងអនុសញ្ញាស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិ (CISG) និងគោលការណ៍នៃកិច្ចសន្យាពាណិជ្ជកិច្ចកម្ម (UNIDRIOT)។ ក្នុងនោះ សេចក្តីព្រាងក្រមរដ្ឋប្បវេណីត្រូវបានរៀបចំឡើងដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹង សិទ្ធិនិងកាតព្វកិច្ចដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ និងសេរីភាពក្នុងការដោះដូរទំនិញផ្អែកតាមកិច្ចសន្យា រួមទាំងបទប្បញ្ញត្តិដែលគ្រប់គ្រងលើទំនាក់ទំនងញាតិ អាពាហ៍ពិពាហ៍ គ្រួសារ សន្តតិកម្មជាដើម។ ក្រុមការងាររៀបចំក្រម បានប្រើប្រាស់ក្រមរដ្ឋប្បវេណីជប៉ុន បារាំង និងអាល្លឺម៉ង់ (Continental Law) ជាគំរូចម្បង និងជាឯកសារយោង ក្នុងការសិក្សានិងវិភាគមុននឹងជ្រើសរើសយកបទប្បញ្ញត្តិ ឬវិធានណាមួយសម្រាប់អនុវត្តនៅកម្ពុជា និងពិនិត្យលើបទប្បញ្ញត្តិដែលមានស្រាប់ដូចជា ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ក្រឹត្យច្បាប់លេខ៣៨ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ និងច្បាប់ភូមិបាលឆ្នាំ២០០១ (ច្បាប់ដែលទទួលឥទ្ធិពលពីបារាំង) រួមទាំងគិតគូរលើបរិបទប្រវត្តិសាស្ត្រ និងទំនៀមទម្លាប់ប្រពៃណីខ្មែរផងដែរ។

---

[35] Hitotsubashi University, Assistance for Legal and Judicial Development: A Decade Spent Creating Autonomous Cambodian Codes of Civil Law and Procedure," Hit-u.ac.jp (Hitotsubashi University, 2018), https://www.hit-u.ac.jp/eng/hq/2011/index.html.

[36] MONG Monichariya and TANAKA Kazuko, "Drafting a New Civil Code and Code of Civil Procedure in Cambodia with Japanese Technical Assistance," Uniform Law Review Volume 7, no. Issue 4 (December 1, 2002), Page 1050-1051.

ចំពោះក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានតាក់តែងឡើងដោយគោរពលើគោលការណ៍ដូចខាងក្រោម៖[37]

១. ខ្លឹមសារនៃសេចក្ដីព្រាងច្បាប់ ត្រូវតែស្របទៅនឹងនីតិវិធីដែលកំពុងអនុវត្តជាក់ស្ដែងនៅក្នុងប្រទេសកម្ពុជា និងត្រូវបញ្ចូលនូវគោលការណ៍នីតិវិធីនៃប្រទេសដែលលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។
២. សេចក្ដីព្រាងក្រម ត្រូវតែធ្វើឡើងដោយមានការចូលរួមពីប្រទេសទាំងពីរ ដោយសេចក្ដីព្រាងដែលត្រូវបានផ្ដួចផ្ដើមដោយក្រុមការងារជប៉ុន និងត្រូវយកមកពិភាក្សាជាមួយក្រុមការងារកម្ពុជា ហើយចុងក្រោយត្រូវបានអនុម័តដោយគោរពតាមមតិយោបល់របស់ក្រុមការងារកម្ពុជា។
៣. ការអនុវត្តក្រមនេះ គឺជាភារកិច្ចរបស់ជនជាតិខ្មែរ។

ក្នុងនោះ សេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីបានណែនាំនូវគោលការណ៍គ្រឹះដូចជា៖ (១) គោលបំណងនៃបណ្ដឹងរដ្ឋប្បវេណី, (២)ការធានានូវសិទ្ធិក្នុងការទទួលបានកិច្ចការពារពីតុលាការ (សិទ្ធិពឹងពាក់តុលាការ), (៣)ការធានានូវសិទ្ធិក្នុងការទាមទារឱ្យមានសវនាការ, (៤)គោលការណ៍ដេញដោលទល់មុខគ្នា (Principle of La Contradiction), (៥)នីតិវិធីរដ្ឋប្បវេណី និងប្រព័ន្ធគណៈវិនិច្ឆ័យ(មិនត្រូវបានអនុម័តឡើយ ដោយសារភាពខុសគ្នានៃការអនុវត្ត), (៦)ការរៀបចំអង្គការតុលាការជាន់ទាប(សាលាដំបូង), (៧)វិសាលភាពនៃគោលការណ៍សវនាការជាសាធារណៈ និង (៨)វិធីសាស្ត្រនៃការចាត់តាំងចៅក្រមឱ្យទទួលបន្ទុកលើសំណុំរឿង។

ក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦ ហើយក្រមរដ្ឋប្បវេណី ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧។ យោងតាមមាត្រា ៩៣ កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ត្រូវចូលជាធរមានក្នុងរយៈពេល ១០ ថ្ងៃនៅរាជធានីភ្នំពេញ និង ២០ ថ្ងៃនៅទូទាំងប្រទេស បន្ទាប់ពីកាលបរិច្ឆេទនៃការប្រកាសឱ្យប្រើ។ យ៉ាងណាមិញ មាត្រា ១៣០៥ នៃក្រមរដ្ឋប្បវេណី បានចែងថា ក្រមរដ្ឋប្បវេណីត្រូវចាប់ផ្ដើមអនុវត្តចាប់ពីកាលបរិច្ឆេទដែលត្រូវកំណត់ដោយឡែកដោយច្បាប់ផ្សេងទៀត។ ក្នុងន័យនេះ ច្បាប់ស្ដីពីការអនុវត្តក្រម នឹងកំណត់អំពីចំណុចចាំបាច់សម្រាប់ការអនុវត្តក្រមរដ្ឋប្បវេណី រួមទាំងវិធានអន្តរកាលពាក់ព័ន្ធនឹងការអនុវត្តច្បាប់នេះដោយឡែកពីរដ្ឋធម្មនុញ្ញ។ គោលបំណងសំខាន់គឺ ដើម្បីទុករយៈពេលសមស្របមួយដើម្បីផ្សព្វផ្សាយដល់សាធារណៈជន និងដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងរដ្ឋប្បវេណីដែលមានស្រាប់ និងគ្រប់គ្រងដោយច្បាប់មុនៗ ហើយដែលមានខ្លឹមសារផ្ទុយនឹងក្រមរដ្ឋប្បវេណី។[38]

---

37 NOP Kanharith , Legal Development in Cambodia before and after Japanese Assistance , n.d., page 3-5.
38 Ibid.

## ១.២. ក្រមព្រហ្មទណ្ឌ

ការរៀបចំក្រមព្រហ្មទណ្ឌក្រោមកិច្ចសហប្រតិបត្តិការរវាងបារាំងនិងក្រសួងយុត្តិធម៌ ត្រូវបាន ចំណាយពេលជាង១០ឆ្នាំ គឺចាប់តាំងពីឆ្នាំ១៩៩៨ រហូតមកដល់ឆ្នាំ២០០៨។ ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ បានរៀបចំឡើងក្នុងគោលបំណងរក្សាឱ្យបាននូវសណ្តាប់ធ្នាប់ សន្តិសុខសុវត្ថិភាពសម្រាប់ សង្គមកម្ពុជា រួមទាំងកំណត់ប្រភេទនៃបទល្មើសនិងទណ្ឌកម្មដែលត្រូវទទួល។ ក្រមនេះដើរតួនាទី យ៉ាងសំខាន់ក្នុងការការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ ដោយធានាថាជីវិត កិត្តិយស និង ទ្រព្យសម្បត្តិរបស់បុគ្គលម្នាក់ៗត្រូវបានការពារពីការរំលោភបំពាន និងជួយបង្ការ និងទប់ស្កាត់ បទល្មើសកើតឡើងនាពេលខាងមុខ។ នៅក្នុងការអនុវត្តជាក់ស្តែង ក្រមព្រហ្មទណ្ឌ មានគោលដៅ សំខាន់សម្រាប់តុលាការ និងអាជ្ញាធរ ក្នុងការពិនិត្យ និងសម្រេចសេចក្តីប្រកបដោយយុត្តិធម៌ ដោយ ធានាថាអ្នកប្រព្រឹត្តបទល្មើសទទួលទណ្ឌកម្មសមស្របទៅនឹងកំហុសដែលបានប្រព្រឹត្ត និងការពារអ្នក គ្មានកំហុសមិនឱ្យរងអំពើអយុត្តិធម៌។

ក្រមព្រហ្មទណ្ឌ ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃសង្គមកម្ពុជា ដែលតម្រូវឱ្យមានបទដ្ឋានគតិយុត្តមួយច្បាស់លាស់ ពេញលេញ គ្រប់ជ្រុងជ្រោយ ប្រយុទ្ធប្រឆាំង ប្រកបដោយប្រសិទ្ធភាព ដែលឆ្លើយតបទៅនឹងទម្រង់ថ្មីនៃបទល្មើសក្នុងសង្គម និងឧក្រិដ្ឋកម្ម ផ្សេងៗដែលបានកើតឡើងជាក់ស្តែង និងនៅថ្ងៃអនាគត។ ដោយសារក្រមព្រហ្មទណ្ឌ ជាអត្ថបទច្បាប់ មួយដែលប្រមូលផ្តុំនូវរាល់បទប្បញ្ញត្តព្រហ្មទណ្ឌដោយមានការបែងចែកជារចនាសម្ព័ន្ធត្រឹមត្រូវ ធានានូវ សង្គតិភាព ភាពរលូន និងស៊ីសង្វាក់គ្នា ព្រមទាំងបំពេញបន្ថែមនូវអ្វីដែលខ្វះចន្លោះនោះ បានធ្វើឱ្យក្រម នេះក្លាយជាឧបករណ៍គតិយុត្តមួយដ៏មានសារៈសំខាន់ ដែលមិនត្រឹមតែផ្តល់ឱ្យមន្ត្រីតុលាការ និងមន្ត្រី អនុវត្តច្បាប់ផ្សេងទៀត ងាយស្រួលក្នុងការប្រើប្រាស់ និងស្វែងយល់ឱ្យបានស៊ីជម្រៅក្នុងវិស័យព្រហ្មទណ្ឌ ប៉ុណ្ណោះទេ ថែមទាំងឱ្យប្រជាពលរដ្ឋ បានយល់ដឹងកាន់តែច្បាស់អំពីសិទ្ធិ និងព្រំដែននៃការអនុវត្តសិទ្ធិ របស់ខ្លួន ជាពិសេសយល់ពីអំពើដែលត្រូវបានហាមឃាត់ និងផ្តន្ទាទោសជាបទល្មើសព្រហ្មទណ្ឌ។

ក្រសួងយុត្តិធម៌បានរៀបចំក្រមនេះដោយផ្អែកលើគោលការណ៍ធំៗនៃច្បាប់ប្រពៃណី ច្បាប់ អន្តរជាតិ បទប្បញ្ញត្តិព្រហ្មទណ្ឌដែលមានស្រាប់ និងបរិបទថ្មីៗ ដែលកំពុងប្រឈមនាពេលនោះ។ ឈរ លើមូលដ្ឋាននេះ ក្រមព្រហ្មទណ្ឌត្រូវបានបង្កើតឡើងដោយគិតគូរអំពីគោលការណ៍ចម្បងៗពាក់ព័ន្ធ ដោយផ្ទាល់ និងដោយប្រយោលទៅនឹងនីតិព្រហ្មទណ្ឌដែលមានចារឹកក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ កម្ពុជា និងក្នុងបណ្តាបទដ្ឋានអន្តរជាតិនានាដែលកម្ពុជាបានទទួលស្គាល់ និងផ្តល់សច្ចាប័ន។ ក្រម ព្រហ្មទណ្ឌនេះ ត្រូវបានតាក់តែងឡើងដោយគោរពគោលគំនិតសំខាន់ៗរបស់ក្រមព្រហ្មទណ្ឌចាស់ និងប្រព័ន្ធច្បាប់រ៉ូម៉ាំង-អាឡឺម៉ង់ ដែលជាប្រពៃណីច្បាប់ព្រហ្មទណ្ឌកម្ពុជា។ ដើម្បីធានាដល់គោល ការណ៍នីត្យានុកូលភាពនៃច្បាប់ព្រហ្មទណ្ឌ ការរៀបចំក្រមព្រហ្មទណ្ឌថ្មីត្រូវបានចងក្រងជាលម្អិត ដោយមានចូលរួមពិភាក្សាពីសំណាក់អ្នកច្បាប់កម្ពុជា និងអ្នកបច្ចេកទេសបារាំង ក្នុងការកំណត់

គោលការណ៍ទូទៅ និងប្រភេទបទល្មើសនីមួយៗឱ្យបានសព្វគ្រប់ និងជាក់ច្បាស់ បញ្ចៀសរាល់អំពើទាំងឡាយណាដែលបំផ្លាញដល់សង្គមឱ្យបានរួចផុតពីការដាក់ទណ្ឌកម្ម។

ក្រមព្រហ្មទណ្ឌត្រូវបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ និងដោយព្រឹទ្ធសភា នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ហើយត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។ ការអនុម័ត និងការប្រកាសឱ្យប្រើនេះជាសក្ខីភាពមួយនៃសមិទ្ធផលក្នុងការធ្វើទំនើបនីយកម្មក្របខ័ណ្ឌច្បាប់ និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌស្របតាមគោលនយោបាយកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។**

បច្ចុប្បន្ន ក្រសួងយុត្តិធម៌ បាននឹងកំពុងសិក្សាធ្វើវិសោធនកម្ម ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងគោលបំណងធ្វើទំនើបកម្មច្បាប់ ដើម្បីឆ្លើយតបនឹងស្ថានភាពសង្គម-សេដ្ឋកិច្ចបច្ចុប្បន្ន ពង្រឹងយុត្តិធម៌ និងបង្កើនប្រសិទ្ធភាពនីតិវិធីតុលាការ។

### ១.៣ ក្រមបរិស្ថាននិងធនធានធម្មជាតិ (ក្រមបរិស្ថាន)

ក្នុងឆ្នាំ២០១២ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានសម្រេចផ្តួចផ្តើមកំណែអភិបាលកិច្ចបរិស្ថាន ដើម្បីលើកកម្ពស់ចីរភាពបរិស្ថាននិងរក្សានូវការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស។ ជាផ្នែកមួយនៃដំណើរការកែទម្រង់នេះ កម្ពុជាបានចាប់ផ្តើមធ្វើការកែសម្រួលគួរឱ្យកត់សម្គាល់លើច្បាប់ជាច្រើនទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ។ ភាគច្រើននៃច្បាប់ទាំងនេះត្រូវបានរៀបចំតាក់តែងក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ហើយបានបង្ហាញអំពីតម្រូវការរបស់រាជរដ្ឋាភិបាលក្នុងការលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ច ក្នុងអំឡុងពេលនៃការកសាងជាតិឡើងវិញបន្ទាប់ពីការបំផ្លិចបំផ្លាញ និងការបាក់រលំនៃនីតិរដ្ឋមួយក្រោមអំណាចរបបខ្មែរក្រហមក្នុងចុងទសវត្សរ៍ឆ្នាំ១៩៧០។

ក្រមបរិស្ថាននិងធនធានធម្មជាតិ ត្រូវបានផ្តួចផ្តើមរៀបចំឡើងជាលើកដំបូងនៅឆ្នាំ២០១៥ ក្រោមការដឹកនាំរបស់ក្រសួងបរិស្ថាន ដោយមានគោលបំណងបង្កើតក្របខ័ណ្ឌច្បាប់មួយដែលមានឯកសណ្ឋានភាព និងគ្រប់ជ្រុងជ្រោយសម្រាប់អភិបាលកិច្ចបរិស្ថាន ការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព។ ការរៀបចំតាក់តែងក្រមបរិស្ថាននិងធនធានធម្មជាតិនេះបង្ហាញឱ្យឃើញអំពីកំណែទម្រង់មួយនៃកំណែទម្រង់ច្បាប់ដ៏គួរឱ្យកត់សម្គាល់បំផុតក្នុងប្រវត្តិសាស្ត្រសម័យទំនើបរបស់ព្រះរាជាណាចក្រកម្ពុជា។ ក្រមនេះកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរពនិងប្រតិបត្តិតាមក្នុងការពង្រឹង ធ្វើទំនើបកម្ម ធ្វើឱ្យមាន សង្គតិភាព និងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងលើកិច្ច

គាំពារបរិស្ថាន ការអភិរក្ស និងស្តារឡើងវិញនូវធនធានធម្មជាតិ ជីវៈចម្រុះ មុខងារប្រព័ន្ធអេកូឡូស៊ី ដើម្បីការរស់នៅនិងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[39]

ក្រមនេះឆ្លុះបញ្ចាំងអំពីកើរ្តិ៍ដំណែលប្រព័ន្ធច្បាប់ស៊ីវិលរបស់កម្ពុជា ខណៈពេលដែលក្រមនេះបានបញ្ចូលខ្លឹមសារមួយចំនួនពីយុត្តាធិការប្រព័ន្ធច្បាប់អង់គ្លូសាក់សុង និងបទដ្ឋានច្បាប់បរិស្ថានអន្តរជាតិ។ ការរួមបញ្ចូលគ្នាទាំងនេះបង្ហាញអំពីការរួមចំណែកនៃច្បាប់ បរិស្ថានជាសកល និងការរក្សាទំនៀមច្បាប់ជាតិក្នុងការអនុវត្តច្បាប់។ សេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ ជាសេចក្តីព្រាងក្រមមួយដែលមានលក្ខណៈចម្រុះ និងគ្រប់វិស័យ ដោយប្រមូលផ្តុំរាល់បទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ដោយមានការបែងចែកជារចនាសម្ព័ន្ធត្រឹមត្រូវ ដើម្បីធានាឱ្យមានសង្គតិភាព និងភាពស៊ីសង្វាក់គ្នា និងព្រមទាំងបានទទួលបន្ថែមនូវចំណុចខ្វះចន្លោះ ភាពមិនច្បាស់លាស់ នៃការគ្រប់គ្រងធនធានធម្មជាតិរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា នៃព្រះរាជាណាចក្រកម្ពុជា ពោលគឺធ្វើយ៉ាងណាឱ្យសេចក្តីព្រាងក្រមមួយនេះ ក្លាយជាលិខិតតុបករណ៍គតិយុត្តមួយយ៉ាងសំខាន់សម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងអ្នកអនុវត្តច្បាប់ផ្សេងទៀតមានភាពងាយស្រួលក្នុងប្រើប្រាស់ និងអនុវត្តតួនាទី ភារកិច្ចរៀងៗខ្លួន។

ក្នុងការតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិនេះ ក្រសួងបរិស្ថាន បានបង្កើតក្រុមការងារចំនួន៥ រួមមានដូចខាងក្រោម៖

១. ក្រុមការងារតាក់តែងសេចក្តីព្រាងក្រមបរិស្ថានអន្តរក្រសួង៖ មានភារកិច្ច និងតួនាទីសម្របសម្រួលការងារពាក់ព័ន្ធនឹងដំណើរការនៃការសម្រេចចិត្តធំៗ ពាក់ព័ន្ធនឹង វិស័យបរិស្ថាន និងធនធានធម្មជាតិជាពិសេស ក្នុងករណីមានការខ្វែងគំនិតគ្នាក្នុងការបែងចែកសមត្ថកិច្ចគ្រប់គ្រងនានាលើធនធានធម្មជាតិ។

២. ក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន៖ ដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំការងារសម្របសម្រួលផ្នែកខ្លឹមសារបច្ចេកទេស ដែលមានសមាសភាពសមាជិកចម្រុះពីក្រសួង ស្ថាប័នរដ្ឋពាក់ព័ន្ធ ដែលសុទ្ធតែជាមន្ត្រីជំនាញបច្ចេកទេស។

៣. លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន៖ មានតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលការងាររបស់ក្រុមការងារជំនាញបច្ចេកទេស នៃក្រុមការងារតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ ដែលមានសមាសភាពជាមេធាវី ចៅក្រមសាលាឧទ្ធរណ៍ និងអ្នកជំនាញការជាតិនិងអន្តរជាតិ ដែលទទួលបន្ទុកលើការតាក់តែងសេចក្តីព្រាងក្រមបរិស្ថានឱ្យមានលក្ខណៈជាបច្ចេកទេសច្បាប់ស្របតាមបរិបទនៃព្រះរាជាណាចក្រកម្ពុជា។

---

[39] *Environmental and Natural Resources Code of the Kingdom of Cambodia (2023),* art. 1.

៤. ក្រុមការងារពិនិត្យ និងកែសម្រួលសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ៖ ក្រុមការងារជំនាញទាំង៧ នៃក្រុមការងារតាក់តែងសេចក្តីព្រាងក្រមបរិស្ថានរួមមាន ក្រុមការងារបឋមដែលមានសមាជិកចម្រុះ ក្នុងនោះមានសមាជិកពីក្រសួងបរិស្ថាន ក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ។ ក្រុមការងារជំនាញនេះ ដើរតួនាទីចម្បងក្នុងការស្រាវជ្រាវ និងប្រមូលមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីចងក្រងជាទិដ្ឋភាពរួមនៃគោលការណ៍បច្ចេកទេស និងបទពិសោធន៍នានាពាក់ព័ន្ធនឹងការអនុវត្តជាក់ស្តែង ដែលជាបញ្ហាប្រឈម ដែលត្រូវយកមកដោះស្រាយ ដោយបទប្បញ្ញត្តិនៃសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ។

៥. ក្រុមការងារជំនាញបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាននិងធនធានធម្មជាតិចំនួន៧ មានជាអាទិ៍៖ ក្រុមការងារជំនាញនិរន្តភាពទីក្រុង និងសេដ្ឋកិច្ចបៃតង, ក្រុមការងារគ្រប់គ្រងសំណល់ និងការបំពុល, ក្រុមការងារអភិរក្ស រុក្ខឧទ្យានសត្វព្រៃ និងជីវៈចម្រុះ, ក្រុមការងារអភិរក្សបេតិកភណ្ឌ និងឧទ្យានធម្មជាតិ, ក្រុមការងារគ្រប់គ្រងដីសើម និងអភិរក្សជីវៈចម្រុះទឹកសាប និងទឹកប្រៃ, ក្រុមការងារគ្រប់គ្រង ស្រាវជ្រាវ និងអាជីវៈកម្មរ៉ែ និងក្រុមការងារអភិរក្សកិច្ចការស្រាវជ្រាវ អប់រំ និងផ្សព្វផ្សាយព័ត៌មានបរិស្ថាន។ បន្ថែមពីនេះ ក្រុមមេធាវី វ៉ិស្ត្រ ជាស្ថាប័នឯកជនដែលសម្របសម្រួល ប្រមូលមតិយោបល់ ជាតុចូល និងអនុសាសន៍ ពីគ្រប់ក្រុមការងារជំនាញ និងសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីយកមកចងក្រង តាក់តែង កែសម្រួលជាបន្តបន្ទាប់។

ជារួម ក្រមបរិស្ថាន និងធនធានធម្មជាតិ ត្រូវបានសម័យប្រជុំលើកទី៩ នីតិកាលទី៦ បានធ្វើការពិភាក្សា និងអនុម័ត នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា ដោយមានវត្តមានសមាជិកសមាជិការដ្ឋសភា ពេលចាប់ផ្តើមសម័យប្រជុំ ចំនួន១០០រូប។ ក្រមបរិស្ថាន និងធនធានធម្មជាតិនេះ គឺប្រមូលផ្តុំសំយោគបញ្ចូលគ្នានូវបទប្បញ្ញត្តិនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមានពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធនធម្មជាតិ ដោយធ្វើសមាហរណកម្ម សុខដុមនីយកម្ម និងទំនើបកម្ម ឱ្យមានភាពជាក់ស្តែងនិយម សង្គតិភាព វិសាលភាពទូលំទូលាយគ្រប់ជ្រុងជ្រោយ និងភាពស៊ីសង្វាក់ប្រទាក់ក្រឡាគ្នា ដើម្បីក្លាយជាបទប្បញ្ញត្តិគោលដែលបានកំណត់ពីដែនសមត្ថកិច្ចនៃក្រសួង ស្ថាប័នពាក់ព័ន្ធ សំដៅសម្របសម្រួលដល់ការអនុវត្តមុខងារ និងតួនាទីភារកិច្ចរៀងៗខ្លួន ក្នុងស្មារតីឯកភាពជាតិ ស្របទៅនឹងការរីកចម្រើននៃសង្គមកម្ពុជាថ្មី។

ក្រមបរិស្ថាននិងធនធានធម្មជាតិនេះបានបំពេញបន្ថែម និងមានភាពស៊ីសង្វាក់ប្រទាក់ក្រឡាគ្នាជាមួយនឹងច្បាប់ពាក់ព័ន្ធនានាដូចជា ក្រមព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្ម ធនធានរ៉ែ ច្បាប់ភូមិបាល ច្បាប់ស្តីពីទេសចរណ៍

ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក។ល។ ក្នុងគោលដៅបន្តជំរុញដំណើរការអភិវឌ្ឍប្រទេសជាតិ និងការពង្រឹងនីតិរដ្ឋទៅកាន់ដំណាក់កាលថ្មីនៅលើមាគ៌ាចីរភាព។

ក្នុងន័យនេះ ក្រមបរិស្ថាន និងធនធានធម្មជាតិត្រូវបានតាក់តែងឡើងដោយផ្អែកលើគោលការណ៍សំខាន់៣ រួមមានទី១)៖ លិខិតបទដ្ឋានគតិយុត្តក្នុងវិស័យបរិស្ថាន និងធនធានធម្មជាតិត្រូវបានធ្វើសមាហរណកម្ម, ទី២៖ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវបានធ្វើសុខដុមនីយកម្ម និងទី៣៖ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាត្រូវបានធ្វើទំនើបកម្ម ឱ្យឆ្លើយតបនឹងនិន្នាការវិវត្តនៃសង្គម។

## ឧបសម្ព័ន្ធទី២ គម្រោងរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា

| ជំហាន | សកម្មភាព | សេចក្តីណែនាំលម្អិត[40] |
|---|---|---|
